# អាល់ប៊ុមគំនិត

ភាគពីរ

៥០០ គំនិតសម្រាប់គិតលេង

ហួត សេងគៀ

# អាល់ប៊ុមគំនិត
# ភាគពីរ

៥០០ គំនិតសម្រាប់គិតលេង

រក្សាសិទ្ធិគ្រប់យ៉ាងដោយអ្នកនិពន្ធ ហួត សេងគៀ

ឆ្នាំ 2017

# មាតិកា


ទំព័រដើម

អាល់ប៊ុមគំនិត ភាគមួយ

ការសរសេរប្លុក

គំនិត

ទំព័រចុងក្រោយ

អំពីអ្នកនិពន្ធ

# ទំព័រដើម

អ្នកនិពន្ធ ប្រៀបបាននឹងឃ្លាំងផលិតគំនិត ប៉ុន្តែគំនិតទាំងនោះមិនប្រាកដថាប្រើកើតទាំងអស់ទេ។ គំនិតខ្លះ ត្រូវការយកទៅសាកល្បងម្ដងហើយម្ដងទៀតទើបអាចដឹងថា ល្អ ឬមិនល្អ។ អ្នកនិពន្ធ បានគំនិតទាំងនោះមកពី បទពិសោធន៍ បូករួមនឹងចំណេះដឹងដែលមានក្នុងខ្លួន ហេតុនេះ ទើបអ្នកនិពន្ធម្នាក់ៗ មានគំនិតខុសគ្នា។

ខ្ញុំក៏ជាអ្នកនិពន្ធម្នាក់ដែរ។ ទោះបីខ្ញុំមិនមានគំនិតច្រើនដូចគេមែន តែវាល្មមនឹងអាចយកមកចែករំលែកបាន។ សៀវភៅនេះជាការប្រមូលយកគំនិតដែលខ្ញុំបានសរសេរក្នុងរយៈពេលពីរឆ្នាំ នៅលើប្លុករបស់ខ្ញុំ។ ពីរឆ្នាំ ខ្ញុំមានតែប៉ុណ្ណឹងទេ។ ពេលជួបនឹងរឿងអ្វីមួយ ខួរក្បាលខ្ញុំនឹងចាប់ផ្ដើមធ្វើការ ហើយរៀបចំជាគំនិតចេញមក។

គំនិតនៅក្នុងនេះ អាចប្រើតែឯងបាន ដោយមិនបាច់យកទៅផ្គុំនឹងគំនិតផ្សេងទៀត។ គំនិតខ្លះខ្លី ខ្លះវែង ទៅតាមការចង់ពន្យល់របស់ខ្ញុំ។ ពេលណា ខ្ញុំចង់សរសេរវែង ខ្ញុំសរសេរវែង ពេលណាខ្ញុំមិនចង់ ខ្ញុំក៏មិនពន្យល់អ្វីដែរ។ ដោយសារខ្ញុំជឿថា អ្នកអានសៀវភៅ មានសមត្ថភាពអាចស្វែងយល់បាន ទើបខ្ញុំមិនបាច់ពន្យល់ច្រើន។ ការអាន ជាការពន្យល់ខ្លួនឯង ហេតុនេះ យើងត្រូវរៀនម្ដងបន្តិចៗ។

សៀវភៅនេះ ជាការចែករំលែករបស់ខ្ញុំប៉ុណ្ណោះ។ ខ្ញុំក៏យកទៅ post លើអ៊ីនធឺណេតដែរ តែវាមិនល្អដូចរៀបចំជាសៀវភៅនោះទេ។ អ្វីដែលគេអានក្នុងថ្ងៃនេះ នឹងលែងមានអ្នកឃើញក្នុងពេលមួយអាទិត្យ ព្រោះមានគេ post ច្រើនពេក ប៉ុន្តែសៀវភៅ គឺខុសគ្នា។ ពេលណាទំនេរ គេអាចយកមកអានឡើងវិញបាន។

ខ្ញុំចូលចិត្តរៀបចំគ្រប់យ៉ាងជាសៀវភៅ ដើម្បីងាយស្រួលអាន និងងាយស្រួលចែករំលែកបន្ត។

ខ្ញុំមិនចង់ឱ្យអ្នកទាំងអស់គ្នា ប្រញាប់អានវាឱ្យចប់ក្នុងពេលមួយថ្ងៃនោះទេ ព្រោះសៀវភៅនេះត្រូវការឱ្យយើងគិតច្រើន។ ត្រឹមតែមួយសន្លឹក ឬពីរ ក្នុងមួយថ្ងៃ គឺល្មមសម្រាប់ខួរក្បាលរបស់យើងធ្វើការលេងៗហើយ។ បើអានឆាប់ចប់ តែមិនយល់ ឬមិនចាំអ្វីសោះ ក៏មិនមានប្រយោជន៍អ្វីដែរ។ អានតាមសម្រួល ហើយកុំភ្លេចយកទៅគិតផង។

ហួត សេងគៀ

# អាល់ប៊ុមគំនិត ភាគមួយ

កាលពីប៉ុន្មានឆ្នាំមុន ខ្ញុំបានចងក្រងជាសៀវភៅមួយក្បាលដែលមានគំនិតជាច្រើន ហើយដាក់ឱ្យគេដោនឡូដ។ ខ្ញុំស្រង់គំនិតទាំងនោះមកពីសៀវភៅដែលធ្លាប់បានអាន។ ខ្ញុំបានដាក់ទាំងចំណងជើងសៀវភៅ និងឈ្មោះអ្នកនិពន្ធនៅក្នុងនោះដែរ តែមិនបានដាក់នៅគ្រប់គំនិតដែលខ្ញុំដកស្រង់ទេ។ សៀវភៅខ្លះ ខ្ញុំអានយូរពេក ភ្លេចឈ្មោះ ហេតុនេះក៏មិនបានដាក់។

ក្រោយពេលដាក់ឱ្យដោនឡូដហើយ មានគេប្រាប់ខ្ញុំថា អ្វីដែលខ្ញុំកំពុងធ្វើនេះបានរំលោភសិទ្ធិអ្នកដទៃហើយ។ គេខំសរសេរ ហើយខ្ញុំចាំតែយករបស់គេមកដាក់ចូលគ្នាបែបនេះ មិនល្អទេ។ ទោះបីខ្ញុំមិនលក់មែន តែវាប៉ះពាល់ស្នាដៃរបស់គេដដែល។ ខ្ញុំយល់ពីចំណុចនេះច្បាស់ណាស់ ព្រោះអ្នកដែលបង្កើតស្នាដៃណា ក៏ចេះស្រលាញ់ និងការពារស្នាដៃរបស់គេ។

ខ្ញុំក៏ដកសៀវភៅនោះចេញពីលើអ៊ីនធឺណេតវិញ ហើយប្រាប់ឱ្យអ្នកអានផ្សេងទៀត ឈប់ចែករំលែកសៀវភៅនោះ។ ខ្ញុំដឹងថាមានអ្នកយកទៅបង្ហោះលើអ៊ីនធឺណេត តែខ្ញុំគ្មានវិធីទេ។ ខ្ញុំធ្វើគ្រប់វិធីដែលខ្ញុំអាចធ្វើទៅបានហើយ។

នេះជាកំហុសមួយរបស់ខ្ញុំ ដែលខ្ញុំចាំមកដល់ឥលូវនេះ។ ខ្ញុំក៏ចេះខ្មាសគេដែរ ព្រោះគំនិតក្នុងនោះជារបស់គេសោះ តែខ្ញុំបែរជាយកមកដាក់ឈ្មោះខ្លួនឯង។ អ្នករៀបរៀង គ្មានអ្វីយកមកប្រៀបនឹងអ្នកនិពន្ធបានទេ។ ម្ចាស់គំនិត ទើបមានសិទ្ធិធ្វើគ្រប់យ៉ាងលើគំនិតរបស់គេ។ ខ្ញុំក៏មិនចង់ធ្វើជាមនុស្សស៊ីពេរគេដែរ។ សៀវភៅភាគពីរនេះ អាចចាត់ទុកថា ជាការដឹងខ្លួនខុសរបស់ខ្ញុំ។

ក្នុងនេះ ជាគំនិតរបស់ខ្ញុំទាំងស្រុង។ គំនិតទាំងនេះ មិនមែនខ្ញុំអង្គុយរកនឹកសរសេរចូលម្តងមួយនោះទេ។ ខ្ញុំគ្រាន់តែដកស្រង់ពីអត្ថបទដែលសរសេរក្នុងរយៈពេលពីរឆ្នាំ នៅលើ ប្លុករបស់ខ្ញុំ ប៉ុណ្ណោះ។ អត្ថបទទាំងនោះមានប្រធានបទខុសគ្នាច្រើនណាស់ ហើយមិនមែនគ្រប់អត្ថបទទាំងអស់ សុទ្ធតែមានគំនិតល្អនោះទេ។ អត្ថបទខ្លះ ខ្ញុំគ្រាន់តែសរសេររៀបរាប់ពីអ្វីដែលខ្ញុំបានជួបប៉ុណ្ណោះ។ បើអ្នកទាំងអស់គ្នាមានពេលទំនេរ អាចចូលទៅអានបាន ព្រោះខ្ញុំមានអត្ថបទថ្មីរាល់អាទិត្យ។

# ការសរសេរប្លុក

ខ្ញុំសរសេរប្លុកប៉ុន្មានឆ្នាំហើយ។ ខ្ញុំទុកវាជាកន្លែងរក្សាគំនិតរបស់ខ្ញុំ និង ចែករំលែកទៅកាន់អ្នកដែលចូលចិត្តអានសំណេររបស់ខ្ញុំ។ ខ្ញុំក៏ប្រើវាជាដើម្បី អភិវឌ្ឍជំនាញសរសេរសៀវភៅរបស់ខ្ញុំផងដែរ។ សៀវភៅនេះកើតពីការ សរសេរប្លុកទាំងស្រុង។

ការសរសេរប្លុក មិនមែនល្អសម្រាប់តែអ្នកនិពន្ធទេ។  មនុស្សទូទៅ ឬអ្នក ដែលមានជំនាញផ្សេងក៏អាចទាញយកប្រយោជន៍ពីវាបានដូចគ្នា។ នៅពេល យើងចាប់ផ្ដើមសរសេរ យើងចាប់ផ្ដើមគិត។ ពេលគិតមិនចេញ យើងនឹងសួរ គេ។ ពេលសួរគេមិនបានចម្លើយ យើងនឹងចាប់ផ្ដើមស្រាវជ្រាវដោយខ្លួនឯង។ ការស្រាវជ្រាវនេះហើយ ដែលធ្វើឱ្យយើងកាន់តែដឹងរឿងច្រើន និងស្ទាត់ ជំនាញ។

ប្លុក ជាអ្នកប្រាប់គេថា យើងជាអ្នកណា ហើយយើងអាចធ្វើអ្វីបានខ្លះ។ ប្លុក មិនដូចបណ្ដាញសង្គមទេ ព្រោះគ្មានអ្នកជឿថាយើងមានជំនាញពិតប្រាកដ ទេ បើមួយថ្ងៃៗ យើងនៅតែលើបណ្ដាញសង្គម។ ម្យ៉ាងទៀត បណ្ដាញសង្គម មិនមែនជារបស់យើង ដូច្នេះយើងមិនអាចគ្រប់គ្រងវាបានទាំងស្រុងដូចប្លុក ទេ។

យើងអាចប្រើប្លុកមក promote ខ្លួនយើង ឬជំនាញរបស់យើងក៏បាន។ ខ្ញុំប្រើប្លុកដើម្បីឱ្យអ្នកដទៃដឹងថា ខ្ញុំជាអ្នកនិពន្ធ ហើយខ្ញុំមានសៀវភៅសម្រាប់លក់។ ខ្ញុំដាក់សៀវភៅនៅលើនោះ ដូច្នេះអ្នកដែលបានឃើញ គេអាចនឹងចាប់អារម្មណ៍ ឬទិញសៀវភៅរបស់ខ្ញុំ។

ខ្ញុំជឿថា បើយើងចំណាយពេលខ្លះទៅលើប្លុក យើងនឹងអាចបានផលច្រើនត្រលប់មកវិញ និងបានរៀនពីបច្ចេកវិទ្យាច្រើនផង។ ផលទាំងនោះ អាចមិនមែនជាលុយកាក់ តែវានឹងធ្វើឱ្យយើងសប្បាយចិត្ត។

អ្នកដែលចង់រៀនបន្ថែមពីការសរសេរប្លុក អាចចូលទៅអានលើវេបសាយ Copyblogger បាន។ វេបសាយនេះនឹងបង្រៀនយើងគ្រប់យ៉ាងពីការសរសេរប្លុក និងធ្វើឱ្យវាល្បី។ គេមិនបង្រៀនយើងពីការផុសរឿងសិចដូចអ្នកបង្រៀនមួយចំនួនមែន ប៉ុន្តែគេបង្ហាញយើងពីរបៀបធ្វើប្លុកពិតប្រាកដ។

# គំនិត

1. មនុស្សស៊ីជោរ ត្រូវការមនុស្សអែបអប។

2. ជឿខ្ញុំចុះ គ្មានអ្នកណាចូលចិត្តមនុស្សអត់បានការទេ។

3. មនុស្សអត់បានការ ចូលចិត្តរិះគន់គេ។

4. ការរិះគន់បែបស្លាបនារបស់មនុស្សអត់បានការ ជាការមើលងាយការខំប្រឹងរបស់អ្នកដទៃ ដោយគិតថាខ្លួនធ្វើត្រូវ ខ្លួនជាមនុស្សល្អដែលបាននិយាយពីចំណុចអាក្រក់របស់អ្នកដទៃចំៗបែបនេះ។

5. សាលារៀន ជាកន្លែងដែលលើកស្ទួយមនុស្សពូកែអែបអប ហើយទម្លាក់មនុស្សដែលរៀនពូកែពិតប្រាកដ។

6. សត្វឆ្កែ ទោះបីជាពាក្យខោអាវស្អាតបាត ពាក់វ៉ែនតា ក៏នៅតែជាឆ្កែ មនុស្សទោះបីជាស្រោត គួរមុខឆ្កែ ក៏នៅតែជាមនុស្ស។

7. មនុស្សអត់បានការ ចូលចិត្តធ្វើរឿងអត់បានការ។

8. កុំភ្លេច សមត្ថភាព ធ្វើឱ្យមនុស្សមានតម្លៃ តែយើងក៏ត្រូវតែចេះបង្ហាញវាឱ្យគេដឹងផង។ បើមិនអ៊ីចឹងទេ យើងនៅតែអត់តម្លៃដដែលហ្នឹង។

9. បរាជ័យ ជារបស់គ្មានន័យសម្រាប់ជីវិត ការធ្វើអ្វីដែលយើងស្រលាញ់ ទើបជារបស់មានន័យ។

10. អ្នកអានល្អ ត្រូវចេះចែករំលែក។ សូមធ្វើខ្លួនជាអ្នកអានល្អគ្រប់គ្នា ដើម្បីការរីកចម្រើនរបស់មនុស្សជាតិ។

11. កុំកំណាញ់នឹងការចែករំលែក ព្រោះនេះមិនមែនជាទម្លាប់របស់អ្នកអានទេ។

12. ការរៀនសូត្រ មិនមែនរៀនតែពីបុគ្គលដែលមនុស្សគ្រប់គ្នាសរសើរថាល្អនោះទេ។ ជួនកាល មនុស្សដែលគេគ្រប់គ្នាជេរ ក៏យើងអាចរៀនបានដែរ។

13. ការជ្រើសរើសសៀវភៅអាន ប្រៀបដូចជារាប់អានមិត្តដែរ បើរើសខុស យើងនឹងមានបញ្ហា។ អ្នកខ្លះអានសៀវភៅហើយ ទៅជាទន់ជ្រាយ ខ្លាចមុខខ្លាចក្រោយក៏មាន ព្រោះខ្លឹមសារក្នុងសៀវភៅមានឥទ្ធិពលខ្លាំងណាស់។

14. ល្បិច មិនមែនអាក្រក់ទាំងអស់នោះទេ បើសិនជាយើងធ្វើដោយមិនឱ្យប៉ះពាល់អ្នកដទៃ។ ល្បិចខ្លះរឹតតែល្អទៀត ដូចជាល្បិចដែលធ្វើឱ្យអ្នកដទៃក្លាហាន ធ្វើឱ្យអ្នកដទៃស្វែងយល់ដោយខ្លួនជាដើម។

15. ការរៀនពីមនុស្សដែលគ្រប់គ្នានិយាយថាក្បត់ ក៏មិនមែនជាដើមហេតុដែលធ្វើឱ្យយើងក្លាយជាមនុស្សក្បត់ដែរ បើចិត្តយើងល្អ។

16. នៅក្រោមជើងគេ សញ្ញាបត្រប្រៀបដូចជាក្រដាសធម្មតា។

17. តួនាទីរបស់មនុស្ស គឺទទួលរឿងល្អផង និងរឿងអាក្រក់ផង។ បើមិនចេះទទួលរឿងអាក្រក់ទេ មួយជីវិតនេះ នឹងរស់នៅដោយស្រែកថ្ងូររកជំនួយពីអ្នកដទៃរហូត ឬគិតថា ជីវិតនេះអយុត្តិធម៌ណាស់។

18. សត្វឆ្កែដែលចូលចិត្តស៊ីឆ្អឹង អាចមើលដឹងថានោះជាឆ្អឹង ទោះបីឆ្អឹងនោះកប់ក្នុងដី ឬប្រលាក់យ៉ាងណាក៏ដោយ ។

19. មនុស្សកំសាក មិននិយមទទួលស្គាល់អ្វីនោះទេ។

20. ជនកំសាក ជាមនុស្សដែលមើលពីសំបកក្រៅដូចជាក្លាហាន ហ៊ានណាស់តែមិនស្គាល់កាលៈទេសៈ និងគ្មានការទទួលខុសត្រូវ។ ជនកំសាក ជាមនុស្សចូលចិត្តបំភ័យ មិនត្រឹមតែខ្លួនឯងទេ នៅបំភ័យអ្នកនៅក្បែរខ្លួនទៀត។ ជនកំសាក ចូលចិត្តធ្វើអ្វីមួយមិនដាច់ស្រេច ហើយចាត់ទុកថា នោះជាការមានហេតុផលត្រឹមត្រូវរបស់ខ្លួន។

21. មនុស្សយើងកើតមក គ្មានកំណត់ឈ្មោះអ្នកណាជាម្ចាស់បញ្ញាលើក្បាលទេ ។

22. ការផ្ដល់តម្លៃដល់ភាពសុខសាន្តក្នុងជីវិត ក៏ជាចំណុចល្អមួយរបស់ស៊ីម៉ាអ៊ីដែរ។

23. កុំបង្ខំខ្លួនឯងឱ្យចូលចិត្តអ្វីដែលយើងស្អប់ ព្រោះវាដូចជាការហែកមាត់ខ្លួនឯង ហើយព្យាយាមញាត់ម្ហូបដែលយើងខ្ពើមចូលអ៊ីចឹង។

24. ខ្លួនយើងស្អប់ស៊ីម៉ាអ៊ី តែមិនបានស្អប់ខ្លួនឯងទេ ដូច្នេះអ្វីដែលល្អ គួរតែប្រមូលដាក់ខ្លួនខ្លះទៅ។

25. ខ្ញុំជាមនុស្ស ដូច្នេះមិនអាចសរសេរត្រូវគ្រប់ជ្រុងទេ។

26. អត់យើងមួយ ក៏សាសនាមិនដួលទៅណាដែរ។ ខ្វះអីមនុស្ស បិទភ្នែកដើរ។

27. បើអ្នកទាំងអស់គ្នា មិនជឿសាសនាទេ ដើរចេញពីសាសនាទៅ។

28. ខ្មែរយើងយក សាសនាជាឈ្នាន់ រកលុយ បិទបាំងការពិត និងដើម្បីចូលសង្គមជាមួយគេប៉ុណ្ណោះ។

29. មនុស្សងប់នឹងសាសនាកម្រិតណាក៏ដោយ ក៏ជាមនុស្សគ្រោះថ្នាក់ដែរ ហេតុនេះបើយើងមិនអាចធ្វើអ្វីពួកគេបានទេ កុំចូលរួមនឹងពួកគេ។ ចូរកុំធ្វើឱ្យខ្លួន ជាមនុស្សគ្រោះថ្នាក់ ដោយសារតែខួរក្បាលយើងត្រូវគេពង្វក់។

30. បើយើងមិនជឿលើសាសនាដទៃ ហើយយើងមិនមានបញ្ហាអ្វីកើតឡើង យើងក៏មិនបាច់ជឿសាសនាដែលគេបញ្ចូលក្នុងខួរក្បាលយើងដែរ។

31. Atheism បដិសេធចោលរាល់សាសនា និង ជំនឿផ្សេងៗ ដែលបិទមនុស្សនៅក្នុងប្រអប់ងងឹតមួយ។ ប្រអប់នោះ គឺ ការមិនចេះគិត។

32. ជំនឿ ប្រៀបដូចជាក្មេងដែលស្លៀកខោទឹកនោមពីតូចអ៊ីចឹង ពេលធំទៅជើងកន្ទែកដើរមិនជិត ដូច្នេះកុំទុកយូរ ។

33. Atheism នឹងផ្លាស់ប្តូរការគិតរបស់យើងទាំងស្រុងដែលតាមពិត យើងមិនធ្លាប់គិតដោយខ្លួនឯងម្តងណាទេ។

34. Atheism មិនគម្រាមយើង ឬ កុហកយើងថា ត្រូវចុះនរកទេ គឺយើងខ្លួនឯងជាអ្នកយល់ពីវា។ ពេលយល់ហើយ គឺ ចូលដោយខ្លួនឯង។ ស្តាប់ទៅដូចជា LDP ដែរ តែខុសគ្នាត្រង់ athiest មិនត្រូវការគេមកដឹកក្បាលក្នុងការរស់នៅទេ។

35. កុំភ័យខ្លាច atheism ធ្វើឱ្យសាសនានៅស្រុកខ្មែររលំ ព្រោះវាជារឿងដែលទៅមិនរួច។ ខ្មែរស្អប់ជាងគេ គឺ ការផ្លាស់ប្តូរ។ ម្នាក់ៗបានតែមាត់និង ចង់ឱ្យអ្នកដទៃផ្លាស់ប្តូរប៉ុណ្ណោះ។

36. ការធ្វើតាមគ្នា ដោយបានគិតជាមុន បញ្ជាក់ថា យើងចេះមើលឃើញទំនោរល្អដែលនាំប្រយោជន៍ក្នុងរយៈពេលយូរ។

37. ការធ្វើតាមគេដោយមិនគិត ឬហៅថាដោរតាមគ្នា គ្មានប្រយោជន៍ត្រលប់មកវិញទេ។ ភាគច្រើន គឺយកលុយឱ្យគេប៉ុណ្ណោះ។ មនុស្ស

ប្រភេទនេះ មិនចេះគិត ហើយខ្លាចសង្គមមិនទទួលស្គាល់ខ្លួន ទើបប្រឹងធ្វើឱ្យដូចគេ។

38. ស្រុកយើង ជា ស្រុកជោរ ប៉ុន្តែជោរបានតែរឿងអាក្រក់ប៉ុណ្ណោះ។ ឱ្យតែរឿងហ្នឹងមានផលប៉ះពាល់ ដឹងតែមានមនុស្សបាក់ទ័ពទៅហើយ។

39. ឃើញភ្លាម ធ្វើតាមភ្លាម មិនឱ្យម្ចាស់ដើមខកបំណងទេ។ ដោយសារតែខ្មែរបែបនេះទើបជំនួញបែបស៊ីវិល័យជាច្រើន មកបើកដំណើរ អាចដើរយ៉ាងរលូន។ អ្នករកស៊ី ចូលចិត្តរកស៊ីក្នុងស្រុកយើងណាស់ ព្រោះស្រួលយកលុយ ។

40. គេមិនឃាត់នឹងរឿងធ្វើតាមគេទេ តែមុននឹងធ្វើ រៀនគិតផង ព្រោះរឿងខ្លះមិនមានប្រយោជន៍ដល់យើងទេ។

41. យើងនឹងបាត់បង់សេរីភាព ព្រោះតែការដើរតាមគេរហូត។

42. LDP មិនមែនរិះគន់សាសនាទេ គឺរិះគន់អ្នកបោកស៊ីក្នុងសាសនា ឬហៅតាមពាក្យពួកគេថា "ចោរថង់យាម ។" ចោរថង់យាម មិនមែនជាពាក្យអាក្រក់ទេ តែពាក្យចំៗ ។ ដោយសារយើងមិនទម្លាប់នឹងភាពស្មោះត្រង់ ហេតុនេះ យើងមិនអាចទទួលពាក្យចំបែបនេះបាន។

43. អ្នកនយោបាយ និងសាសនា មិនអាចចែកដាច់គ្នាបានទេ ព្រោះពួកគេត្រូវការអ្វីដែលអាចគ្រប់សង្កត់ប្រជាជនបាន។ បើអំណាចរបស់

អ្នកនយោបាយ គ្រប់គ្រងប្រជាជនមិនជាប់ គេនៅមានសាសនា ធ្វើជាផ្លូវក្រោយ។

44. សាសនា ជាជម្ងឺរបស់កម្ពុជាដែលនាំឱ្យយើងជាប់គាំងក្នុងការផ្លាស់ប្តូរផ្នត់គំនិត។ តើយើងប្តូរផ្នត់គំនិតយ៉ាងម៉េចកើត បើយើងនៅតែទ្បប់ឆ្កួតនឹងនិញ្វន្ទ និង នរកដែលមិនមានពិត ហើយយកវត្ថុជាកន្លែង លាងបាបនោះ?

45. បើសាសនានៅតែមាន មនុស្សនៅតែត្រូវគេពង្វក់ខួរក្បាល ហើយនៅតែចាត់ទុកអ្នកដទៃ ជាអ្នកដឹកនាំរហូត។

46. រស់នៅជាចៀម ព្រោះខ្លាចធ្លាក់នរក។

47. ខ្ញុំមិនជឿលើសេរីភាពក្នុងការបញ្ចេញមតិមែន តែខ្ញុំជឿលើសេរីភាពក្នុងការគិត។

48. បើយើងគិតថា យើងត្រូវការអ្នកដទៃមកអង្គុយឱ្យយើងថ្វាយបង្គំ បានន័យថា ក្នុងចិត្តយើងនៅតែជាទាសកររបស់គេដដែល។

49. មនុស្សពេលជួបបញ្ហា គេមិនឱ្យលុតជង្គង់ទេ គេឱ្យក្រោកឈរឡើងតតាំង តែសាសនាមិនបង្រៀនយើងបែបនេះទេ។ ថ្វាយបង្គំ ជ្រះអស់បញ្ហា។

50. ការស្លាប់ សង្គ្រាម ភាពរឹករិរ ការចាយលុយអត់ប្រយោជន៍ ពត៌មានប្រឌូកប្រឌល់ ការជំពាក់បំណុលបរទេស ការលក់មុខជាតិ និងមុខមាត់អាក្រក់ៗ សុទ្ធតែចេញពីអ្នកនយោបាយ។

51. អ្នកនយោបាយ កើតពីការលាយចូលគ្នា រវាងពេស្យាចារ ចោរកម្ម និងការពង្វក់ខួរក្បាល។ ពួកគេលក់បានគ្រប់វិធី លួចបានគ្រប់ពេល និងលាក់បានគ្រប់រឿង។

52. ខ្ញុំឯកភាព នឹង LDP ទៅលើរឿងសាសនា ប៉ុន្តែខ្ញុំមិនជឿនយោបាយរបស់ពួកគេ។ ពួកគេដកជំនឿពីសាសនា ដើម្បីដាក់ចូលបក្សរបស់ខ្លួន។ អ្នកដឹកនាំណាក៏ដោយ មិនចង់ឱ្យអ្នកក្រោមបង្គាប់បែងចែកជំនឿច្រើនផ្លូវពេកទេ។

53. ខ្ញុំមើល ទៅកាន់សាសនា និងបក្សនយោបាយ ដូចគ្នានឹងពួកគេមើលមកកាន់ខ្ញុំដែរ។

54. ការចូលសាសនា និងបក្សនយោបាយ មិនជួយឱ្យយើង ចេះគិត ឬក្លាយជាមនុស្សល្អទេ។ បើយើងភ្លើ ចូលទៅថាតាមគេដូចសេក លក់ដល់អស់ពីខ្លួនទៀត ក៏គ្មានបានអីមកវិញដែរ។

55. ខួរក្បាលមានរៀងខ្លួន បើស្រលាញ់សាសនាណាស់ បង្កើតសាសនាមួយខ្លួនឯងទៅ។ យ៉ាងហោចណាស់ យើងបានពង្វក់ខួរក្បាលគេគ្រាន់បើជា ងគេមក ពង្វក់យើង។

56. សាសនា ក៏ជាជំនួញមួយដែរ គ្រាន់តែអ្នកធ្វើជំនួញនេះកំសាក លួចស៊ី លាក់មុខនៅពីក្រោមម៉ូតសក់ និង ម៉ូតសម្លៀកបំពាក់ប្លែកភ្នែក ប៉ុណ្ណោះ។ យើងអាចនឹងមានគោលការណ៍សហគ្រិនភាពថ្មីមួយទៀត គឺ "បង្កើតសាសនា រកលុយពីសាសនារបស់ខ្លួន ល្អជាងធ្វើតាមគេ"។

57. ដេកស៊ីដោយសារគេហើយ បង្គាប់គេឱ្យឱនក្បាល តើគេហៅថាមនុស្ស ល្អដែរទេ?

58. យើងគួរតែទុកអ្នកសាសនា ជាអ្នករកស៊ីទើបត្រូវជាង ហើយប្រើ ទ្រឹស្តី "អតិថិជន ជាស្តេច" ជាមួយពួកគេវិញ។ បើចង់ឱនក្បាល មិនមែន យើងដែលជាអ្នកចេញលុយត្រូវធ្វើទេ។ សាសនា គួរតែគោរពអតិថិជន ផង ព្រោះគេចាយលុយអស់ច្រើនណាស់។

59. ចង់ចេះចង់ដឹង ខ្ញុំចេះរៀនដោយខ្លួនឯង។ ខ្ញុំមានលុយទិញសៀវភៅ អាន ចុះឈ្មោះរៀនអនឡាញ និងមានមាត់សួរអ្នកដែលគេចេះជាង។

60. ជំនឿខ្ញុំ គឺនៅលើខ្លួនឯង។ ចង់អ្នកណាពូកែនិយាយអីក៏ពូកែទៅ ខ្ញុំមិន ខ្វល់ទេ។

61. គេមានទ្រឹស្តី ខ្ញុំក៏ចេះបង្កើតទ្រឹស្តីដែរ។ គេគិតថាខ្លួនគេអស្ចារ្យ ខ្ញុំក៏ គិតថាខ្លួនខ្ញុំអស្ចារ្យដែរ។ គេមានបក្ស មានអ្នកគាំទ្រ ខ្ញុំអត់មាន ខ្ញុំគាំទ្រ ខ្លួនឯង ក៏បានដូចគ្នា។

62. ក្រោយពេលខ្ញុំមិនជឿលើព្រះ និងសាសនា ខ្ញុំត្រូវជឿលើខ្លួនឯង។

63. ខ្ញុំមិនជឿថាមានជាតិក្រោយ ដូច្នេះខ្ញុំប្រឹងធ្វើគ្រប់យ៉ាងតាមដែលអាចធ្វើទៅរួច មុនពេលស្លាប់ទៅវិញ។ ខ្ញុំធ្វើប្រញាប់ណាស់ ព្រោះខ្លាច ធ្វើមិនទាន់។ ខ្ញុំគ្មានពេលច្រើនដូចអ្នកដទៃ ព្រោះគេជឿថាជាតិក្រោយ គេនឹងបន្តខ្សែជីវិតគេម្តងទៀត ។

64. ពីមុន ពេលមានអ្វីមិនល្អកើតឡើង ខ្ញុំគិតថា វាជាកម្មពីជាតិមុនរបស់ខ្ញុំ។ ឥលូវនេះ ខ្ញុំត្រូវរកឱ្យឃើញពីមូលហេតុដែលនាំឱ្យរឿងអាក្រក់នោះកើតឡើងដើម្បីដោះស្រាយវា។

65. មិនមែនថារឿងនិទានក្នុងសាសនា មិនល្អនោះទេ តែយើងមិនអាចអានរឿងប្រឌិតពេញមួយជីវិតបាន។ យើងត្រូវការរៀនពីការពិតឱ្យច្រើនជាងរឿងប្រឌិត។

66. គេរស់ក្នុងការស្រមៃជាមួយព្រះ ខ្ញុំរស់ក្នុងការស្រមៃរបស់ខ្លួនឯង។

67. ខ្ញុំគ្មានសង្ឃឹមថាបានទៅនិពាន្វទេ ដូច្នេះរាល់ថ្ងៃខ្ញុំប្រឹងរស់ឱ្យមានន័យហើយមិនរំពឹងថា ដល់តែស្លាប់ទៅទើបបានសុខដូចអ្នកដទៃដែរ។

68. ខ្ញុំលែងបានប្រកែកជាមួយអ្នកដទៃពីរឿងសាសនាទៀតហើយ ព្រោះខ្ញុំដឹងថាវាគ្មានប្រយោជន៍ដល់ខ្ញុំ។ បើខ្ញុំប្រកែក បានន័យថាខ្ញុំក៏មិន ខុសពីពួកគេដែរ។

69. ការដេញដោលគ្នា ជារឿងសប្បាយ បើសិនជាភាគីម្ខាងទៀត មានការចេះដឹង និងចេះវែកញែកដោយពឹងលើការពិត ប៉ុន្តែបើម្ខាងទៀត មានខួរ

កាត់ទៅបង្គង ការសន្ទនានេះ មិនខុសពីឆ្កែព្រុសលេងជាមួយមនុស្សទេ ។

70. លុយ មិនមែនជារឿងសំខាន់បំផុតក្នុងជីវិតមែន ប៉ុន្តែវានៅតែជារឿងសំខាន់ ដូច្នេះយើងមិនអាចមិនរវល់នឹងវាបានទេ។ យើងកាន់តែមិនអើពើ វាកាន់តែចេញឆ្ងាយពីយើង។

71. មានលុយក្នុងដៃ ល្អជាងមិនមានអ្វីសោះ។

72. មិនថាយើងឱ្យតម្លៃទៅលើអ្វីទេ កុំភ្លេច ត្រូវមានលុយជាប់ខ្លួនផង។

73. លុយអាចកំនត់ភាពថ្លៃថ្នូររបស់មនុស្ស។

74. លុយអាចទិញបានគ្រប់យ៉ាង មិនថាស្នេហា ការសិក្សា ភាពរីករាយ មិត្តភាព កេរ្តិ៍ឈ្មោះ សម្រស់ និងសូម្បីតែជីវិត។ អ្វីដែលសំខាន់ ស្ថិតលើអ្នកដែលមានលុយនោះ ចេះប្រើខួរក្បាលដល់កម្រិតណា? លុយពេលប្រើជាមួយខួរក្បាល ប្រៀបដូចជាម៉ាស៊ីនបូមដីដ៏ធំមួយដែលអាចស្រូបយកគ្រប់យ៉ាងបាន ។

75. ចំណាយមិនល្អ នឹងនាំទុក្ខដល់យើង។

76. ចាយតាមតម្រូវការ កុំចាយតាមការដោរតាមគ្នា។

77. អ្នកមាន គេមិនងាយនឹងប្រាប់យើងពីរបៀបរកលុយទេ។ គេអាចប្រាប់យើងថា ធ្វើបែបនេះ ធ្វើបែបនោះ តែវិធីដែលគេធ្វើពិតប្រាកដ គឺគ្មានថ្ងៃ

ចេញពីមាត់គេឡើយ។ បើមានមែន យើងនឹងឃើញគេចុះកាសែតថា "ឧកញ៉ា ក និយាយពីរឿងយកស្រីក្មេងផ្គាប់ចិត្តឧកញ៉ា ខ ដើម្បីចុះកុងត្រា" ឬ "ប្រធានក្រុមហ៊ុន ក និយាយពីរបៀបដាក់លុយក្រោមតុនៅតាមក្រសួង ដើម្បីសម្រេចការងារបានលឿន"។ គន្លឹះក្នុងការរកលុយ គឺលាក់គន្លឹះក្នុងការរកលុយ។

78. ទ្រឹស្ដីច្រើន មិនអាចរកលុយបានទេ លើកលែងតែយើងយកទ្រឹស្ដីទាំងនោះទៅបោកគេក្នុងសិក្ខាសាលាប៉ុណ្ណោះ។ សិក្ខាសាលា ជារបៀបដែលគេរកលុយ ហើយជារបៀបដែលយើងចាយលុយ។ បើយើង មានគំនិតបើកសិក្ខាសាលា នោះយើងចេះដឹងពីលុយច្បាស់ហើយ។

79. ជំនាញដែលត្រូវទីផ្សារ បានលុយលឿនណាស់។ អ្នកមិនដឹង នៅតែមិនដឹង ហើយខំរៀនជំនាញតាមគ្នាដើម្បីប្រជ្រៀតគ្នាធ្វើការដែលបានលុយតិច។

80. ខ្ញុំមិនជឿលើព្រះទេ តែខ្ញុំជឿថាលុយជាព្រះ។

81. លុយ មានអំណាចណាស់ ជាពិសេសនៅក្នុងដៃមនុស្សឆ្លាត។

82. អ្នកដែលមានលុយច្រើន នឹងធ្វើអ្វីតាមចិត្តរបស់ខ្លួន ដូច្នេះគេមិនបាច់លាក់ពុត ដូចពេលអត់លុយនោះទេ។ លុយ ជាកញ្ចក់ឆ្លុះមើលចរិតមនុស្ស។

83. ខ្ញុំចូលចិត្តអានទាក់ទង នឹងនយោបាយ តែមិនចូលចិត្តតាមដានរឿង របស់អ្នកនយោបាយទេ។ ខ្ញុំមើលមិនឃើញពីប្រយោជន៍ដែលយើង ត្រូវតាមដានរឿងកូនចៅ ឬរឿងសិចរបស់អ្នកនយោបាយសោះ។

84. នយោបាយ ជា រឿងសំខាន់របស់សង្គម តែអ្នកនយោបាយ ជាអ្នក បំផ្លាញរឿងសំខាន់របស់សង្គម។

85. តើអ្នកតំណាងរាស្ត្រ ពិតជាតំណាងឱ្យរាស្ត្រមែនឬអត់?

86. អ្វីដែលរាស្ត្រចង់បាន និងអ្វីដែលតំណាងរាស្ត្រចង់បាន មិនស៊ីចង្វាក់គ្នា សោះ ។ រាស្ត្រចង់យកអំណាចពីអ្នកនយោបាយ ចំណែកតំណាង រាស្ត្រប្រឹងរកអំណាចដើម្បីអ្នកនយោបាយ។ រាស្ត្រចង់បានសេរីភាព តំណាងរាស្ត្រចង់គ្រប់គ្រងសេរីភាព។ រាស្ត្រមិនពូកែបត់បែន ប៉ុន្តែ តំណាងរាស្ត្របត់លឿនជាងចង្កេះទេព បូព្រឹកទៀត។ មើលតែការ ស្លៀកពាក់ និង ការនិយាយស្តី ឬមាយាទ ក៏ដឹងថាតំណាងរាស្ត្រ និង រាស្ត្រគ្មានអ្វីដូចគ្នាដែរ។

87. បក្ស គឺ បក្ស រាស្ត្រ គឺរាស្ត្រ។ រៀនបែងចែកឱ្យច្បាស់ ទើបយើងមិនខាត បង់។ បក្សប្រើរាស្ត្រដើម្បីប្រយោជន៍បាន តែរាស្ត្រមិនអាចប្រើបក្សយក ប្រយោជន៍បានទេ។ ហ៊ានតែចង់ប្រើ ដឹងតែទ្រោមខ្លួនហើយ។

88. តំណាងរាស្ត្រ មិនមែនសម្រាប់រាស្ត្រទេ។ ខ្ញុំឆ្ងល់ណាស់ តើអ្នកណាគេ ដែលឆ្លួតបង្កើតពាក្យនេះឡើងមក? ភាសា អាចបោកមនុស្សបានមែន

។ រាស្ត្រគិតថា តំណាងរាស្ត្រ ជាអ្នកជួយខ្លួន ប៉ុន្តែភ្លេចគិតថា តំណាងរាស្ត្រ នៅតែជាអ្នកនយោបាយ ។

89. អ្នកនយោបាយ យកទ្រឹស្តី "ខ្លួនទីពឹងខ្លួន" ជាធំ ហើយជាក់លាក់ណាស់ ។ គេពឹងខ្លួនគេមកបោកយើង ដើម្បីបានអំណាច។ ពេលបានអំណាចហើយ គេក៏ប្រាប់យើង ឱ្យពឹងខ្លួនឯងដើម្បីរស់ម្តង។

90. មនុស្ស និង តម្លៃបេះគ្នាមិនដាច់ដូចអាចម៍ និងគូថ។

91. ដើម្បីបានតម្លៃមកយើងត្រូវធ្វើ រឿងជាច្រើន។ ក្នុងនោះដែរ ការងារជាផ្នែកមួយដែលបង្កើតតម្លៃឱ្យមនុស្សបាន។ មនុស្សគ្មានការងារធ្វើអាចនឹងត្រូវគេចាត់ទុកថា គ្មានតម្លៃ ឬមិនទាន់មានតម្លៃ។

92. ពេលយើងនិយាយពីតម្លៃ យើងត្រូវនិយាយពីការគោរព ដូច្នេះការងារដែលគ្មានអ្នកណាគោរព គឺជាការងារដែកគ្មានតម្លៃ។

93. ការបោកប្រាស់ដោយយកជំនឿអ្នកដទៃមក ធ្វើជាឈ្នាន់ ត្រូវបានគេគោរព តែវាគ្មានតម្លៃទេ ព្រោះជំនឿបានជួយបិទបាំងការពិត។

94. អ្នកដទៃបានប្រាក់ខែលើសខ្ញុំ បានន័យថា គេមានតម្លៃជាងខ្ញុំក្នុងការងារ ហើយក្រុមហ៊ុនក៏គោរពពួកគេច្រើនជាងខ្ញុំដែរ។ ក្រុមហ៊ុនស្គាល់តម្លៃច្បាស់ជាងយើងស្គាល់ខ្លួនឯងទៅទៀត។ គេមិនចំណាយលុយច្រើនលើ មនុស្សដែលមិនអាចជួយអ្វីគេបានទេ។

95. ជួនកាល យើងគិតវិជ្ជមានលើខ្លួនឯងពេក ហើយច្រលំតម្លៃដែលយើងគិតខ្លួនឯងថាជាតម្លៃពិតប្រាកដ។ យើងអាចនឹងគិតថា ខ្លួនយើងពូកែជាងគេ ឬឆ្លាតជាងគេ ប៉ុន្តែ ត្រូវចាំថា តម្លៃនៅក្នុងការងារ មិនមែនយើងជាអ្នកសម្រេចតែម្នាក់ឯងទេ។ យើងជាអ្នកបង្កើតតម្លៃ និង បង្ហាញតម្លៃ ប៉ុន្តែអ្នកដទៃជាអ្នកឱ្យតម្លៃ។

96. រៀនគិតពីប្រាក់ខែ ឬ ប្រាក់រង្វាន់ យើងនឹងដឹងថា ខ្លួនយើងមានតម្លៃក្នុងការងារប៉ុណ្ណា។

97. សូមកុំឈឺចិត្ត ពេលដឹងថា ការងាររបស់យើង មិនសូវមានតម្លៃ ឬគ្មានតម្លៃ ព្រោះយើងអាចកែប្រែវាបានដោយប្រឹងបន្ថែមតម្លៃបន្តទៀត។ ជំនាញ បទពិសោធន៍ និងការច្នៃប្រឌិត អាចបន្ថែមតម្លៃឱ្យយើងបាន។

98. សាកសួរបុគ្គលិកក្រុមហ៊ុនសិនទ្រីទៅមើលថា ពួកគាត់ពេញចិត្តនឹងការងាររបស់គាត់ដែរទេ? បើគាត់ឆ្លើយថា ពេញចិត្ត គាត់សមនឹង ធ្វើការបែបនោះអស់មួយជីវិតហើយ។

99. រៀនទទួលស្គាល់តម្លៃការងាររបស់ខ្លួន ហើយផ្លាស់ប្តូរវា បើយើងមិនពេញចិត្ត។

100. កុំភ្លេច ខ្លួនយើងមានតម្លៃ ទើបគេគោរពយើង។ មិនមែនឱ្យតែមានការងារធ្វើ យើងមានតម្លៃនោះទេ។

101. ការងារមានច្រើន តម្លៃក៏មានច្រើនដែរ។

102. ហេតុអ្វីមនុស្សយកសត្វធ្វើជាឆ្នាំ ហើយគោរពជំនឿនេះ ប៉ុន្តែ សម្លាប់សត្វធ្វើអាហារ និងធ្វើបាបសត្វ? ខ្ញុំមិនយល់តែម្តង។

103. មានក្តីស្រមៃច្រើន ជារឿងល្អ តែបើគ្រាន់តែមាន ហើយគ្មានមួយណាបានសម្រេច វាប្រៀបដូចជា ចូលដល់បង្គន់ ហើយជុះមិនចេញអ៊ុចឹង។ ខាតពេល!

104. ឈប់ផ្តោតលើអ្វីដែលទៅមិនរួចទៀត ឬអាចទុកវាមួយឡែកសិន រង់ចាំដល់ពេលដែលវាអាចទៅរួចសម្រាប់យើង ចាំយកវាមកធ្វើឡើងវិញ។ អ្វីដែលអាចទៅរួច យើងធ្វើមុន ហើយធ្វើឱ្យលឿន ដើម្បីកែប្រែក្តីស្រមៃដែលទៅមិនរួចខ្លះ ឱ្យក្លាយជាទៅរួចវិញ។

105. ខ្ញុំគោរពមនុស្សដែលមានជំនាញណាស់ ព្រោះខ្ញុំជឿថាពួកគេមានសមត្ថភាពធ្វើអ្វីម្យ៉ាង ។

106. ខ្ញុំមិនអាចគោរពអ្នកដែលមិនធ្វើអ្វីសោះ ឬមិនចេះអ្វីសោះបានទេ ព្រោះធ្វើបែបនេះជាការប្រមាថដល់មនុស្សដទៃទៀតដែលខ្ញុំគោរព។

107. ការរៀនតាមអនឡាញ កំពុងតែពេញនិយមណាស់។ ស្រុកយើងមិនមានការពេញនិយមទេ ព្រោះនេះជារបស់មានប្រយោជន៍។ បើរឿងអត់ប្រយោជន៍ ទើបយើងសម្រុកជាន់គ្នាទៅធ្វើ។

108. ការរៀនអនឡាញ មានប្រយោជន៍ច្រើនណាស់ដូចជា តម្លៃថោកជាងមិនបាច់ចំណាយពេលអង្គុយក្នុងថ្នាក់ មិនបាច់រវល់នឹងការងាររលេង។

ក្នុងសាលា អាចរៀនពេលណាក៏បាន ហើយអ្វីដែលល្អបំផុត គឺ មានជំនាញច្រើនឱ្យយើងរើស។ ខ្ញុំហៅវាថា "ផ្ទះបនមេរៀន" ព្រោះខ្ញុំចង់យកអាមួយណាក៏បានដែរ ឱ្យតែមានលុយគ្រប់។

109. បើរៀនចប់ប៉ុន្មានឆ្នាំ ហើយគ្មានជំនាញដដែល តើយើងចំណាយពេល និង ចំណាយលុយទៅរៀនធ្វើអី?

110. អ្នកដែលចង់បានជំនាញ អាចរៀនតាមអនឡាញបាន។ យើងនឹងក្លាយជាម្ចាស់ពិតប្រាកដលើការសិក្សារបស់យើង។

111. យើងត្រូវពង្រឹងជំនាញដោយខ្លួនឯង ព្រោះជំនាញគ្មានថ្នាំលាបឱ្យរឹងទេ។

112. បទពិសោធន៍ ជាផ្នែកមួយដែលធ្វើឱ្យមនុស្សមានតម្លៃ ។

113. ទោះបីជាប្រទេសយើង ជាប្រទេសពុករលួយ អាងខ្សែ និង ចូលចិត្តយកមនុស្សភ្លើៗទៅធ្វើការធំពិតមែន ប៉ុន្តែយើងក៏មិនភ្លេចដែរពីសារៈសំខាន់នៃបទពិសោធន៍។ យើងត្រូវតែមានបទពិសោធន៍។ បើបានពីក្មេងទៅទៀត រឹតតែល្អ។

114. អ្នកដែលធ្វើការងារតែមួយកន្លែងរាប់ ឆ្នាំមានពីរប្រភេទ គឺ អ្នកដែលស្រលាញ់កន្លែងការងារនោះ និង អ្នកដែលគ្មានសមត្ថភាពរកការងារផ្សេង។

115. គេមិនខ្វល់ថាយើងមកធ្វើការប៉ុន្មានឆ្នាំទេ សំខាន់អំឡុងពេលយើងនៅក្នុងក្រុមហ៊ុនគេ តើយើងអាចធ្វើអ្វីបានសម្រេចខ្លះ។ បើយើងយល់ពីចំណុចនេះ យើងនឹងលែងធ្វើជាឈ្លើងដែលទាមលុយពីក្រុមហ៊ុន រហូតដែរ។

116. បទពិសោធន៍ ជាខ្នងបង្អែករបស់យើងក្នុងការប្តូរការងារ។ បើយើងមានវា យើងមានទឹកមាត់ទៅនិយាយជាមួយគេហើយ។

117. ពេលធ្វើការ កុំភ្លេចប្រឹងធ្វើអ្វីថ្មីឱ្យបានច្រើន ដើម្បីប្រមូលយកបទពិសោធន៍ឱ្យទាន់ពេល ។

118. ជំនាញរបស់យើង មិនអាចឈានជើងទៅណារួចទេ បើយើងមិនធ្វើអ្វីសោះ។

119. បទពិសោធន៍ដែលយើងមាន ប្រៀបដូចជាថ្នាំប៉ូវដល់ជំនាញរបស់យើងអ៊ីចឹង។ អ្នកដែលមានបទពិសោធន៍ក្នុងការងារច្រើនឆ្នាំ ក៏មានជំនាញច្បាស់លាស់ទៅតាមនោះដែរ។

120. គ្រូផ្នែកអាយធីភាគច្រើន ចេះមិនដល់បុគ្គលិកជំនាញផ្នែកអាយធីទេ។ មូលហេតុ ព្រោះតែ បទពិសោធន៍របស់គ្រូ គឺបង្រៀន ចំណែកបទពិសោធន៍អ្នកធ្វើការអាយធី គឺ អាយធី ។

121. បទពិសោធន៍ និងជំនាញ មិនអាចចែកចេញពីគ្នាបានទេ។

122. បើយើងធ្វើការអ្វីមួយ ទើបតែបានប៉ុន្មានខែ ស្នាដៃរបស់យើងមិនអាចស្មើនឹងអ្នកដែលធ្វើរាប់ឆ្នាំនោះទេ។ សំណេររបស់ខ្ញុំ ក៏មិនអាចប្រៀបបាននឹងអ្នកនិពន្ធជើងចាស់ដែរ ព្រោះបទពិសោធន៍របស់ខ្ញុំនៅស្ទើរ ហេតុនេះខ្ញុំសរសេរមិនដល់កម្រិតពួកគេទេ។

123. បទពិសោធន៍ ក៏ជាប្រភពលុយមួយដែរ។

124. មនុស្សឱ្យតម្លៃបទពិសោធន៍ណាស់ ព្រោះនោះជាផ្លូវដើរ។ បើមានគេប្រាប់ពីវិធីធ្វើអ្វីមួយ ដែលគេធ្លាប់ធ្វើពីមុន យើងប្រាកដជាចង់ដឹងមិនខាន ដូច្នេះយើងត្រូវចំណាយលុយដើម្បីបានចំណេះដឹងទាំងនោះមក។

125. បើគ្មានបទពិសោធន៍ថ្មីទេ ខ្ញុំក៏គ្មានអ្វីដើម្បីសរសេរបន្តដែរ។ ខ្ញុំមិនអាចសរសេរពីរឿងសាមកុកបានមួយជីវិតទេ។

126. បទពិសោធន៍ អាចជួយឱ្យយើងរកលុយបានដោយអំពើត្រឹមត្រូវ និងពើងទ្រូងចាយលុយដោយមិនខ្មាសខ្លួនឯងទៀតផង។

127. ពេលយើងមានបទពិសោធន៍ក្នុងជីវិតក៏ដោយ ក្នុងការងារក៏ដោយ យើងនឹងកាន់តែទុកចិត្តខ្លួនឯង ហើយលែងទុកចិត្តអ្នកដទៃ។ យើងនឹងរៀនចេះពាក្យថា "លើលោកនេះ មនុស្សដែលយើងអាចទុកចិត្តបាន គឺខ្លួនយើង"។

128. បទពិសោធន៍ នឹងបង្រៀនយើងគ្រប់យ៉ាង តាំងពីការមើលមនុស្ស ដែលគួរជឿការយល់ពេលវេលា ការបត់បែនដើម្បីយករួចខ្លួន និងវិធី ដោះស្រាយផ្សេងទៀត។

129. បទពិសោធន៍ ជួយខ្ញុំឱ្យមើលឃើញចំណុចខ្វះខាត ហើយជួយបន្ថែម ឱ្យខ្ញុំទៀតផង។

130. គេមិនឱ្យតម្លៃយើងទេ បើយើងជាក្មេងដែលដេកស៊ីលើលុយម៉ែ ឬទើប នឹងរៀនចប់។ គេមិននិយាយតាមត្រង់មែន តែយើងគួរតែដឹងពីរឿងនេះ ដែរ។

131. យើងឱ្យតម្លៃមនុស្សទៅតាមតម្លៃដែលមនុស្សនោះមាន។

132. រកបទពិសោធន៍ឱ្យបានច្រើនហើយ ចាំមើលថាអ្នកដទៃនឹងធ្វើបែបណា ចំពោះយើង។

133. ក្នុងមួយថ្ងៃ យើងអាចបង្កើនបទពិសោធន៍ឱ្យខ្លួនឯង យ៉ាងហោច ណាស់ក៏មួយដែរ។

134. ជំនឿ ជាចំណូលចិត្តរបស់ខ្មែរតាំងពីដើមមក។ ខ្មែរជឿថា បើសែនដូច ចិននឹងរកស៊ីមានបាន ដូចចិនមិនខាន ហេតុនេះទើបរៀនធ្វើតាមគេ។

135. ជំនឿ មិនដែលបង្រៀនយើងឱ្យគេគិត ឬឆ្ងល់ទេ តែវាបង្រៀនឱ្យយើង ជឿ និងជឿដោយងប់ងល់ទៀតផង។

136. ការសែនដោយផ្អែកលើជំនឿនេះហើយ ដែលធ្វើឱ្យខ្មែរក្លាយជា ចិន ដោយមិនចាំបាច់កើតចេញពីគូថចិន (ខ្ញុំដឹងថាមនុស្សមិនកើតពីគូថទេ)។ ចិនមានរបៀបរកលុយរបស់គេ ទោះគេមិនសែន ក៏គេរកលុយបានដែរ។ គេសែន ព្រោះតែគេចង់ឱ្យប្រពៃណីរបស់គេស្ថិតស្ថេរប៉ុណ្ណោះ។

137. ប្រព័ន្ធផ្សព្វផ្សាយ ជា អ្នកបង្កើតទំនោរផ្សេងៗក្នុងសង្គម។

138. ចិនជាពូជអ្នករកស៊ី ដូច្នេះការបោក ឬបង្កើតទីផ្សារឱ្យខ្លួនឯងជា ជំនាញរបស់ពួកគេ។ យើងបញ្ជូនខ្មែរទៅរៀនផ្នែកជំនួញនៅសាកលវិទ្យាល័យ ក៏មិនប្រាកដថាអាចយកឈ្នះចិនដែលមិនធ្លាប់ចូលរៀនផង។

139. ចិនអាចនឹងបោកឱ្យខ្មែរសែនតាមខ្លួន ដើម្បីគេអាចលក់គ្រឿងសែនបានច្រើនជាងមុន។ ភាគច្រើន ចិនជាអ្នកលក់គ្រឿងទាំងអស់នេះ។ គ្រឿងសែនដែលលក់ដាច់ជាងគេជាមួយខ្មែរ គឺ ស្រាបៀរ និងសាច់ក្លែម។

140. ចរិតមួយរបស់ខ្មែរ គឺ ចូលចិត្តចាញ់បោកចិន ហើយអរគុណចិន ទៀត។

141. យើងលើកតម្កើងចិនរហូតមក។ ដល់កម្រិតមួយដែលការលើកតម្កើងនេះ មិនអាចទៅមុខបានទៀត ខ្មែរយើងក៏ប្រឹងប្រែខ្លួនទៅជាចិនដែរ ទាំងចរិត និងទង្វើ។

142. និស្ស័យធ្វើខ្ញុំបរទេសបាន ចាក់គ្រឹះយ៉ាងជ្រៅទៅក្នុងឈាមខ្មែរ។ យើងលើកបរទេសគ្រប់សាសន៍ មិនមែនតែចិន ឬយួននោះទេ។

143. តារាសម្តែង គេបានលុយ តែយើងនាំគ្នាសម្តែងធ្វើចិន បែរជាអស់លុយទៅឱ្យចិនមែនទែនទៅវិញ។

144. វាជាណាចក្រអច្ឆរិយៈ ជាពាក្យសម្តែងប៉ុណ្ណោះ។ ប្រហែលយើងពិតជាអស្ចារ្យមែន ដែលអាចកាត់ទំហំផ្ទៃដីរបស់ខ្លួនឯងបាន ដោយមិនបាច់ប្រើកម្មវិធីជំនួយ។

145. សម្រាប់អ្នកដែលចង់រកស៊ីមានបានដូចចិន ខ្ញុំអាចប្រាប់ពីវិធីមួយចំនួនដូចជា ចេះកេងបន្លំ ចេះបោកប្រាស់ រកខ្នងបង្អែកក្នុងរដ្ឋាភិបាល ចេះពុករលួយកុំឱ្យគេដឹង និងកុំសូវមានមនុស្សធម៌ពេក ឬធ្វើពុតជាមានហើយ post តាមហ្វេសប៊ុកឱ្យច្រើនក៏បានដែរ។

146. ចិនសែនព្រោះវាជាប្រពៃណីរបស់គេ ខ្មែរសែនតាមចិន ព្រោះខ្មែរមិនចេះគិត ចង់មានបានតាមផ្សែងធូប និងក្រដាសដែលទិញមកដុតចោល។

147. បើទាល់តែមានបុណ្យ ទើបអាចជុំគ្នាបាន ទំនាក់ទំនងរបស់គ្រួសារអ្នកទាំងអស់គ្នាមានបញ្ហាហើយ។

148. តើនៅពេលអាន យើងត្រូវប្រើអ្វីច្រើនជាងគេ? គឺ ប្រើខួរក្បាល ។

149. មិនថាសៀវភៅ ឬអានអ្វីក៏ដោយ ការគិតអាចបំលែងទិន្នន័យដែលយើងទទួលបាននោះ ទៅជារបស់ដែលប្រយោជន៍។ បើមិនអាចប្រើបានក្នុងពេលនេះ ក៏អាចនឹងត្រូវប្រើនៅពេលណាមួយដែរ។

150. យើងចេះអាន ព្រោះយើងចេះគិត។ យើងចេះគិត ព្រោះយើងចេះអាន។

151. អ្នកអានដែលមិនគិត ច្រើនតែធ្លាក់ចូលក្នុងការពង្វក់របស់គេ។

152. សំណេរ មានឥទ្ធិពលណាស់។ មេទ័ពចិនសម័យមុន សរសេរជាយុទ្ធសាស្ត្រ ហើយផ្ញើរឱ្យអ្នកដឹកនាំមើលដើម្បីទទួលបានការទុកចិត្ត។ អ្នកនិពន្ធខ្លះ ប្រើសំណេរដើម្បីយកចិត្តមេ ដើម្បីបានប្រយោជន៍។ អ្នកនយោបាយ ប្រើសំណេររបស់អ្នកដទៃដែលរៀបចំឱ្យយ៉ាងស្អាត ដើម្បីឡើងនិយាយទាក់ទាញការគាំទ្រពីរាស្ត្រ។ សំណេរមានឥទ្ធិពលល្អផង អាក្រក់ផង ដូច្នេះបើយើងមិនចេះគិតទេ ត្រៀមខ្លួនរងគ្រោះពីការពង្វក់របស់គេទៅ។

153. ការអានសៀវភៅ មិនមែនជាការប្រណាំងគ្នាទេ ដូច្នេះល្បឿនមិនអាចបញ្ជាក់ពីអ្វីបានទាំងអស់។

154. អ្នកខ្លះអានសៀវភៅច្រើនណាស់ក្នុងមួយឆ្នាំៗ តែនៅមិនដឹងថាការចាយលុយម៉ែយូរពេក ជាទារុណកម្មចំពោះម៉ែឪខ្លួនឯង។

155. អានយឺត ប៉ុន្តែអានយល់ មានប្រយោជន៍ជាងអានចោលហើយមិនយល់អ្វីទាំងអស់។

156. ការអាន និងការគិត ត្រូវដើរជាមួយគ្នា។

157. អ្នកណាថា មនុស្សភ្លើមិនចេះគិត? មនុស្សភ្លើមានការគិតរបៀបរបស់គេ ដែលជួនកាលយើងមិនអាចយល់ផង។

158. ការគិតវិជ្ជមាន ជាការគិតទៅរកផ្លូវល្អ ចំណែកការគិតភ្លើវិញ គឺគិតដើម្បីលួងខ្លួនឯងថាល្អ ប៉ុន្តែដើរទៅរកផ្លូវទាល់ច្រក ។

159. ការគិតវិជ្ជមាន ជាការគិតម៉ត់ចត់រកមើលបញ្ហា និងដំណោះស្រាយច្បាស់លាស់ ចំណែកការគិតភ្លើវិញ គឺគិតបែបអែបអបខ្លួនឯង ដោយមិនហ៊ានប្រឈមមុខនឹងបញ្ហា។

160. ការគិតវិជ្ជមាន ត្រូវការហ្វឹកហាត់ជាប្រចាំ និងធ្វើការតាមការណែនាំរបស់អ្នកជំនាញក្នុងផ្នែកណាមួយ។ ការគិតភ្លើ មិនបាច់ហាត់ទៅរៀនអ្វីទេ ព្រោះបើរៀនចេះទៅ យើងលែងបានគិតភ្លើទៀតហើយ។

161. បើចង់គិតវិជ្ជមាន រកមើលបញ្ហា ឱ្យឃើញមុនសិន ព្រោះបើរកមិនឃើញទេ ការគិតវិជ្ជមានរបស់យើង នឹងក្លាយជាការកគិតភ្លើវិញហើយ ។

162. សន្សំពេលវេលា គឺ សន្សំជីវិត។

163. បណ្តាញសង្គម បានធ្វើឱ្យលែងស្គាល់ ថាអ្វីជារឿងរបស់យើង ហើយអ្វីជារឿងរបស់អ្នកដទៃ។ យើងចំណាយយ៉ាងច្រើន ទៅលើរឿងអ្នកដទៃ ហើយគ្មានពេលធ្វើរឿងខ្លួនឯង។

164. ការថែរក្សាសិល្បៈជាតិ ជារឿងរបស់យើង តែរឿងលក់ខ្លួន ឬលែងលះគ្នារបស់ពួកអ្នកសិល្បៈ មិនពាក់ព័ន្ធនឹងយើងទេ។ យើងត្រូវបែងចែកវាឱ្យដាច់ ទើបមិនខាតពេល។

165. បើយើងទៅរវល់នឹងអ្វីដែលយើងមិនចូលចិត្ត យើងធ្វើឱ្យជីវិតយើងខាតទៅដោយមិនមានតម្លៃ។

166. អ្វីដែលយើងមិនចូលចិត្ត ជាអ្វីដែលយើងគួរជៀសវាង។

167. Debate ជាវិធីស៊ីម៉ោងដែលគេប្រើនៅក្នុងសាលា ឬនៅកន្លែងណាក៏ដោយ។ គេលើកប្រធានបទមួយឡើងមក ហើយឱ្យមនុស្សដែលគិតថាខ្លួនឯងត្រូវ និងមិនចេះទទួលស្គាល់គំនិតអ្នកដទៃឡើងមកនិយាយអួតពីនេះពីនោះ រហូតដល់គ្រប់ម៉ោង គេក៏បញ្ចប់។ មិនថាអ្នកណាយល់យ៉ាងម៉េចទេ ពេលដល់ម៉ោង ត្រូវតែចប់ ដូច្នេះទើប debate ជារឿងអត់ប្រយោជន៍។ Debate ប្រៀបដូចជាការដាក់ឆ្អឹងមួយដើមឱ្យឆ្កែពីរក្បាលដណ្តើមគ្នាស៊ី ហើយដល់ពេលវាខាំគ្នាអស់ចិត្តហើយ គេដកឆ្អឹងនោះចេញវិញ។ ឆ្កែក៏ឈប់ខាំគ្នា។

168. អ្នកណាក៏មានគំនិតដែរ ដូច្នេះមិនបាច់យកវាមកប្រកែកគ្នាទេ។

169. ការនិយាយថា "ទាល់តែអ្នកនិពន្ធ ទើបអាចសរសេរសៀវភៅបាន" ប្រៀបដូចជានិយាយថា "ទាល់តែអ្នកចថតរឿងសិច ទើបអាចរួមភេទបាន" អ៊ីចឹង។ អ្នកណាក៏អាចសរសេរសៀវភៅបានដែរ ឱ្យតែតាំងចិត្តថាចង់សរសេរពិតមែន ។

170. ការសរសេរសៀវភៅ មានលក្ខណៈខុសគ្នាពីការចំនាយពេលសរសេរ status លើហ្វេសប៊ុក ត្រង់វាមានប្រយោជន៍ជាង ។

171. យើងកាន់តែសរសេរច្រើនប៉ុណ្ណា យើងកាន់តែមើលឃើញរឿងដែលគួរឱ្យចាប់អារម្មណ៍ច្រើនជាងមុន។

172. សៀវភៅ ជាស្នាដៃដែលមិនចេះហួសសម័យទេ ព្រោះមនុស្សសម័យ ថ្មីតែងតែចង់ដឹងរឿងពីមុនជានិច្ច ។ លើកលែងតែសៀវភៅ មួយចំនួនប៉ុណ្ណោះ ដែលត្រូវគេទុកចោល ភាគច្រើនជាសៀវភៅលើកជើងអ្នកធំណាម្នាក់។

173. យើងមិនក្លាយជា អ្នកប្រាជ្ញដោយសារសរសេរសៀវភៅទេ ប៉ុន្តែការគិតរបស់យើងនឹងរីកចម្រើនជាងមុន ពេលយើងសរសេរ។

174. អ្នកជំនាញ ជាមនុស្សដែលសិក្សាពីគំនិតអ្នកដទៃ ហើយមានគំនិតខ្លួនឯង ។

175. យើងគួរតែមានសៀវភៅយ៉ាងហោចណាស់មួយក្បាលដែរ ដើម្បីធ្វើជាតំណាងរបស់យើង ក្រោយពេលខ្លួនយើងត្រូវគេដុតបាត់ទៅ។

176. ការសរសេរសៀវភៅ ជាផ្នែកមួយនៃវប្បធម៌ចែករំលែក។ អ្នកខ្លះគិតថា គ្រាន់តែចូលស៊ីចុកក្នុងហាង និងផុសអួតគ្នា ក៏ហៅថាចែករំលែកដែរ។ ត្រូវហើយ! វាជាការចែករំលែកភាពភ្លើរបស់យើងនៅលើអ៊ីនធឺណេត។

177. ជីវិតគ្មានគោលដៅ ប្រៀបដូចជា ឡានដែលគ្មានចង្កូត ប៉ុន្តែបើមានតែគោលដៅ គ្មានបានធ្វើអី ប្រៀបដូចជាឡានជ័រដែលគេដាក់តាំងបង្អួតក្មេងប៉ុណ្ណោះ។

178. គេធ្វើឱ្យយើងគិតថា វាជារឿងពិបាកខ្លាំងណាស់ ទើបគេអាចដកលុយពីហោប៉ៅរបស់យើងបាន។ អ្នកមិនដឹង នៅតែមិនដឹង ហើយគេដែលរកលុយបាន ក៏មិនចង់ឱ្យអ្នកមិនដឹង បានដឹងខ្លួនដែរ។ អ្នកចេះ មិនងាយនឹងបំបែកឆ្នាំងបាយខ្លួនឯងទេ។

179. អ្នកដែលមិនចេះគ្រោងការងារប្រចាំថ្ងៃ មិនអាចធ្វើអ្វីចេញទេ។ អ្វីដែលពួកគេអាចធ្វើបាន គឺផុសអួតនៅក្នុងហ្វេសប៊ុកថា គេនឹងធ្វើរឿងនេះ ឬធ្វើរឿងនោះឱ្យសម្រេច តែតាមពិត ផុះតែអាចម៍ ក៏ផុះមិនអស់ផង។

180. នៅពេលយើងដឹងខ្យល់ យើងក៏អាចដឹងថាខ្លួនយើង មិនដឹងខ្យល់ដែរ។

181. ខ្ញុំប្រឹងធ្វើគ្រប់យ៉ាងដើម្បី កុំឱ្យជាប់ឈ្មោះជាមនុស្សកំសាក។ តែអ្នកខ្លះមិនខ្វល់ពីរឿងនេះទេ ព្រោះគេមានលេសដើម្បីប្តូរពាក្យពីកំសាក មកជាពាក្យអ្វីផ្សេង។

182. ខ្ញុំមិនចូលចិត្តការប្តូរពាក្យ ដើម្បីបិទបាំងបញ្ហាទេ ព្រោះនេះជាទង្វើដែលមានកម្មសិទ្ធបញ្ញារបស់អ្នកនយោបាយ។ កុំចង់លួចរបស់អ្នកនយោបាយ បើគេលួចរបស់យើង គឺបាន។

183. ដោយសារតែបច្ចុប្បន្ន មនុស្សប្រុស យកចរិតមនុស្សស្រីមកប្រើច្រើនពេក ទើបមានការកើនឡើងនៃមនុស្សកំសាកក្នុងសង្គមបែបនេះ។

184. នៅលើហ្វេសប៊ុក មានអ្នកក្លាហានកំសាកច្រើនណាស់ ដែលមិនហ៊ានប្រើរូបពិតរបស់ខ្លួនឯង ហើយដើរបញ្ចេញយោបល់ផ្តេសផ្តាស។ បើតាមមើលយោបល់ទាំងនេះ ពួកគេមិនហ៊ាននិយាយទល់មុខគេទេ ព្រោះខ្លាចត្រូវរបស់គេវិញ។

185. អ្នកដែលធ្វើពុតជាក្លាហាន ស្នេហាជាតិ ឬមានគំនិតនៅលើហ្វេសប៊ុក ជាមនុស្សកំសាកប៉ុណ្ណោះ។ វាជារឿងងាយបំផុត ដោយគ្រាន់តែអង្គុយចុច keyboard ថាឱ្យអ្នកដទៃ ព្រោះយើងមិនចាំបាច់ធ្វើអ្វីឱ្យចេញផលពិតប្រាកដ។

186. យើងមិនមែនកើតមកដើម្បីធ្វើជាជំនាងសាលាទេ។ រៀនចប់ ដើរចេញ។ យើងកើតមកដើម្បីធ្វើកិច្ចការដែលមានប្រយោជន៍ជាងអង្គុយក្នុងថ្នាក់។

187. ការចាយលុយម៉ែឃ្យូរពេក អាចបញ្ជាក់បានរឿងពីរយ៉ាង។ ទីមួយ គឺ ម៉ែយើងស្រលាញ់កូនខ្លាំងពេក។ ទីពីរ គឺយើងជាមនុស្សកំសាក និងអត់បានការ។

188. មនុស្សកំសាក មិនចូលចិត្តមនុស្សមិនកំសាក។ ពួកកំសាក ចូលចិត្តតែគ្នាគេហ្នឹង។

189. គ្មានអ្វីកំសាកជាង ការទ្រពង និងលើកជើងគេនោះទេ។

190. អ្នកខ្លះចង់ការពាររបស់ខ្លួនឯង តែខ្លាចគេថាយើងមិនល្អ ចិត្តមិនទូលាយ។ បើគិតបើនេះ យើងត្រូវទៅពេទ្យពិនិត្យមើលថាខួរក្បាលយើងនៅដើរ ឬអត់។ សូម្បីតែឆ្កែ ក៏ចេះការពារផ្ទះរបស់វាដែរ ចុះទម្រាំយើងជាមនុស្ស?

191. ហេតុផលកំសាក នៅតែបញ្ជាក់ថា យើងជាមនុស្សកំសាកដដែលហ្នឹង។ យើងកាន់តែមានហេតុផលច្រើន យើងកាន់តែកំសាកលើសដើម។

192. ជ្រើសផ្លូវអនាគតដោយខ្លួនឯង ទើបបញ្ជាក់ថាយើងជឿលើភ្នែកខ្លួនឯង។

193. អ្នកដែលចាំព្រះ រដ្ឋាភិបាល ឬអ្នកមានចិត្ត មកជួយជាលុយ ក៏អាចរាប់ថាកំសាកដែរ។

194. ចាំព្រះជួយ កំសាកជាងគេ ព្រោះព្រះ គ្រាន់តែជាការស្រមើស្រមៃរបស់មនុស្សប៉ុណ្ណោះ។

195. មនុស្សកំសាក ខ្លាចការពិត ដូចសម្ដេចខ្លាចគណបក្សប្រឆាំងឈ្មោះ គណបក្សគាត់អ៊ុំចឹង។

196. ឆ្នាំថ្មី ជាឱកាសសម្រាប់សម្រេចការងារដែលយើងមិនអាចធ្វើបានក្នុងឆ្នាំចាស់។

197. សូមឱ្យការគិតរបស់យើង កើនឡើងតាមអាយុរបស់យើងទៅចុះ។

198. ដាក់គោលដៅពីដើមឆ្នាំ ប្រឹងធ្វើវាពេញមួយឆ្នាំ ចាំមើលលទ្ធផលនៅចុងឆ្នាំ។

199. ឆ្នាំថ្មី គ្មានអ្វីអស្ចារ្យទេ បើយើងនៅតែធ្វើខ្លួនដូចឆ្នាំចាស់។

200. លះបង់ភាពភ្លើរបស់យើងចោល យើងនឹងទទួលបានអ្វីថ្មីជាច្រើនក្នុងឆ្នាំថ្មី។

201. មនុស្សម្នាក់ អាចសម្រេចរឿងជាច្រើនក្នុងរយៈពេលមួយឆ្នាំ បើគេមិនផោមចោល។

202. ឆ្នាំថ្មី ជាឆ្នាំដែលត្រូវប្រើខួរក្បាលរបស់យើង។

203. បរាជ័យក្នុងឆ្នាំចាស់ ជារឿងកំប្លែងសម្រាប់ឆ្នាំថ្មី។

204. ផែនការមួយល្អបាន បើពេលចុងឆ្នាំឃើញផលល្អ។

205. កុំបន្ទោសអ្នកដទៃ បើយើងខ្លួនឯងមិនបានធ្វើអ្វីសោះ។

206. រៀនជំនាញថ្មី ឱ្យវាជូនគ្នានឹងពាក្យថាឆ្នាំថ្មី។

207. បិទមាត់របស់យើង ហើយធ្វើតាមផែនការខ្លួនឯង ទើបយើងអាចបិទមាត់អ្នកដទៃបានរហូត។

208. ការវាយតម្លៃខ្លួនឯង ជាការគិតគូរទៅដល់ថ្ងៃក្រោយរបស់យើង។

209. ព្រះផ្ចាញ់មារ យើងគ្រប់គ្នាដែលមានខួរ ផ្ចាញ់មនុស្សភ្លើៗ។

210. ពេលដែលកម្រិតបានការរបស់ខ្ញុំកើនឡើង កម្រិតភ្លើរបស់ខ្ញុំក៏ថយចុះដែរ។

211. មនុស្សមិនបានការ ពេញចិត្តនៅក្រោមជើងអ្នកដទៃរហូត។

212. បើយើងអួត ហើយយើងអាចធ្វើបាន បានន័យថា យើងមិនមែនជាមនុស្សមិនបានការ តែបើបានត្រឹមតែព្រុស ហើយធ្វើអីមិនចេញ គឺយើងគ្មានបានការហើយ។

213. បើអ្វីដែលយើងបានធ្វើមានច្រើនប៉ុណ្ណា បញ្ជាក់ថា យើងជាមនុស្សបានការក្នុងកម្រិតប៉ុណ្ណឹងដែរ។

214. មានលុយ មានភាពរីករាយ ហើយវាកាន់តែរីករាយបើលុយដែលរកបាននោះ មិនចេញពីការលក់ក្បាល ឬទ្រូពង។

215. ខ្ញុំចេះព្រួស ខ្ញុំចេះខាំ។ គិតទៅខ្ញុំក៏មិនចាញ់ឆ្កែដែរ ប៉ុន្តែមនុស្សខ្លះវិញ សូម្បីតែឆ្កែក៏មិនស្មើផង។ ខ្ញុំមានមោទនភាពណាស់ដែលខ្ញុំមិននៅក្រោមស្តង់ដារឆ្កែ។

216. ការបូកសរុបលទ្ធផលគោលដៅប្រចាំឆ្នាំ ជាការរំលឹកប្រាប់ថា យើងបានដើរដល់ចំណុចណាហើយ។

217. បើយើងក្រ ត្រូវប្រឹងដោយខ្លួនឯង កុំចាំព្រះ រដ្ឋាភិបាល ឬអ្នកមានចិត្តសប្បុរសណាមកជួយយើង ព្រោះវាមិនងាយកើតឡើងទេ។ បើព្រះ និង រដ្ឋាភិបាល ដឹងតែអត់ផ្លូវហើយ ចំណែកអ្នកមានវិញ យូរៗលេចមុខមកម្តង មិនល្អទេ។

218. ស្រុកខ្មែររបស់យើងនេះ មិនចូលចិត្តភាពស្មោះត្រង់ទេ។ អ្នកទាំងអស់គ្នាអាចប្រកែកបានតាមចិត្ត ព្រោះអ្នកដែលប្រកែកនឹងចំណុចនេះ អាចបែងចែកចេញជាពីរ គឺ អ្នកដែលមិនស្មោះត្រង់ស្រាប់ និងមនុស្សមិនដឹងខ្យល់។

219. អ្នកដែលមិនស្មោះត្រង់ ខ្លាចអ្នកដទៃដឹងថាខ្លួនមិនស្មោះត្រង់។

220. ធ្វើការយូរបន្តិច ខ្ញុំរៀនចេះរឿងមួយ គឺ ភាពស្មោះត្រង់ ជារបស់ដែលគេមិនចូលចិត្តក្នុងសង្គម។

221. យើងខ្លាចភាពស្មោះត្រង់ណាស់ តែធ្វើពុតជាចូលចិត្ត និងឱ្យតម្លៃលើភាពស្មោះត្រង់ទៅវិញ។ អ្នកនយោបាយ អ្នកសិល្បៈ មនុស្សក្នុងសាសនា និងអ្នករកស៊ី សុទ្ធតែមនុស្សក្នុងប្រភេទនេះ។

222. ក្នុងចំណោមមនុស្ស១០នាក់ យើងអាចរកអ្នកដែលនិយាយថា "ភាពស្មោះត្រង់ ជាគោលការណ៍របស់មនុស្ស" បាន១០នាក់ តែបើចង់រកមនុស្សដែលហ៊ានធ្វើដូចអ្វីដែលគេនិយាយ បើរកបាន២នាក់ ទុកថាជារឿងអស្ចារ្យហើយ។

223. ភាពស្មោះត្រង់ ត្រូវការភាពក្លាហានច្រើនជាងការកាន់កាំភ្លើងចូលប្លន់ធនាគារទៀត។

224. យើងមិនបាច់ចូលសិក្ខាសាលា ឬរៀនយកបណ្ឌិតដើម្បីក្លាយជាមនុស្សស្មោះត្រង់នោះទេ ព្រោះយើងអាចរៀនវាដោយខ្លួនឯងបាន។

225. ហេតុអីគេមិនចូលចិត្ត នៅពេលមានគេថា ប្រទេសខ្មែរសម្បូរមនុស្សភ្លើ និងកំសាក?

226. ពាក្យស្មោះ ទាស់តែត្រចៀកមនុស្សមិនស្មោះត្រង់ប៉ុណ្ណោះ។

227. យើងទាំងអស់គ្នានេះ គាំទ្រគេឱ្យឡើងធ្វើជាអ្នកដឹកនាំ និងជួយបង្កើតអំណាចឱ្យគេ។ ដល់ពេលគេបានអំណាចហើយ គេក៏យកអំណាចនោះមកសង្កត់យើង ហើយដកសិទ្ធិរបស់យើងម្ដងបន្តិចៗ។ យើងខឹង មិនសុខចិត្ត ក៏ចង់ទម្លាក់គេចុះមកវិញ ប៉ុន្តែមិនអាចធ្វើរួច ព្រោះគេឡើង

ខ្ពស់ពេកទៅហើយ។ យើងគិតតែបន្ទោសគេ រហូតភ្លេចថា យើងខ្លួនឯង ជាអ្នកបង្កើតបញ្ហា។

228. អ្នកមានអំណាចចាស់ និងអ្នកមានអំណាចថ្មីជួបគ្នា ក៏ពិភាក្សាគ្នាពីរឿងអំណាច ហើយភ្លេចគិតពីយើង។ មិនយូរប៉ុន្មានគេក៏ធ្វើដាក់យើង ដូចអ្នកមានអំណាចចាស់ដែរ។

229. យើងឱ្យគេបោក ព្រោះយើងគិតថាខ្លួនឯងឆ្លាត ចេះមើលមនុស្ស។

230. អ្នកនយោបាយទាំងអស់ ជាអ្នកដែលហ៊ានលះបង់។ ពួកគេលះបង់មុខមាត់ ពេលវេលា លុយកាក់ ឱកាស កម្លាំងកាយ និងកម្លាំងចិត្ត ដើម្បីបានឡើងទៅដល់កំពូល។ គេលះបង់ទាំងអ្នកដែលគាំទ្រគេ និងធ្លាប់រុញគូថគេទៀតផង ដើម្បីរក្សាអំណាចរបស់គេ។ គេលះបង់អ្វីក៏បានដែរ លើកលែងតែផលប្រយោជន៍ខ្លួនឯង។

231. អ្នកដឹកនាំ កាន់តែខ្ពស់ កាន់តែមិនខ្វល់ពីអ្នកនៅខាងក្រោម ជាពិសេសអ្នកដែលគ្មានប្រយោជន៍ឱ្យគេ។ យើងអាចមិនជឿពីរឿងនេះ ព្រោះយើងលង់ជឿពាក្យពីក្នុងសៀវភៅភាពជាអ្នកដឹកនាំ។ នេះជាការពិត មិនមែនជាពាក្យក្នុងសៀវភៅទេ។ អ្នកដឹកនាំទាំងនោះ មិនធ្វើតាមពាក្យក្នុងសៀវភៅទេ។ ពួកគេជាអ្នកដឹកនាំ គេមិនធ្វើតាមពាក្យអ្នកដទៃឡើយ។ គេធ្វើតាមអ្វីដែលគេគិតឃើញប៉ុណ្ណោះ។

232. កំណើនយ៉ាងឆាប់រហ័សនៃមនុស្សភ្លើ បានធ្វើឱ្យបាត់បង់បរិស្ថាន បាត់បង់សេរីភាព និងសម្លាប់មនុស្សមិនដឹងអីជាច្រើន។

233. សូមកុំច្រលំ ការធ្វើកញ្ជះនយោបាយមិនមែនភ្លើទេ ប៉ុន្តែការលក់ក្បាលទៅដែលភ្លើនោះ។

234. យើងរស់នៅក្នុងពិភពនៃការផ្សាយពាណិជ្ជកម្ម។

235. ផ្សាយអ្វីដែលល្អៗ ឱ្យខ្លួនឯងមើល កុំភ្លើយកអ្វីមិនបានការមកដាក់ក្នុងខ្លួន។

236. ប្រាប់ខ្លួនយើងទៅថា យើងនៅអាចធ្វើបានច្រើនជាងនេះទៀត គ្រាន់តែឥលូវយើងមិនទាន់ទៅដល់កម្រិតនោះ។

237. យើងអាចសន្សំលុយដើម្បីទិញរបស់ប្រើបាន មិនចាំបាច់សង្ឃឹមរង្វាន់ពីស្រាបៀរនោះទេ។

238. ជីវិតយើងដែលរស់នៅរាល់ថ្ងៃនេះ ក៏មានកន្លែងគួរឱ្យចាប់អារម្មណ៍ដែរ ដូច្នេះមិនបាច់ចំណាយពេលតាមដានជីវិតក្លែងក្លាយរបស់ពួកតារាក្នុងទូរទស្សន៍ទេ។

239. មិនមែនមនុស្សស្រីមិនឆ្លាតទេ ប៉ុន្តែមិនហ៊ានឆ្លាត។ ឆ្លាតនៅត្រង់នេះបានន័យថា ប្រើខួរក្បាលរបស់ខ្លួនឯង។

240. អានអ្វីដែលធ្វើឱ្យខួរក្បាលរបស់យើង ងើបធ្វើការវិញ។

241. សៀវភៅ អាចជួយឱ្យយើងនិយាយស្ដីដឹងខ្យល់ជាងមុន និងចេះគិតជាងមុន។ ផ្លាស់ប្ដូរប្រភេទសៀវភៅឱ្យបានច្រើន ដើម្បីកុំឱ្យគំនិតយើងនៅច្រំដែល។

242. មិនថាយើងជាស្រីដែលចូលចិត្តដើរលេង ឬជាស្រីដែលចូលចិត្តដេកផ្ទះទេ សៀវភៅអាចជួយយើងបានទាំងអស់។

243. ចរិតយើងអាក្រក់ ក៏អាក្រក់ចុះ ឱ្យតែខួរក្បាលយើងនៅដើរល្អបានហើយ។ រវាងមនុស្សអាក្រក់ និងមនុស្សភ្លើ ខ្ញុំគិតថាមនុស្សភ្លើជាមនុស្សគ្រោះថ្នាក់ជាង។

244. គិតពីខ្លួនឯងឱ្យបានច្រើន មុននឹងយើងអស់ពេលគិត។

245. ភាពឆ្លាត ជាសម្រស់មួយផ្នែករបស់មនុស្សស្រី។ ស្អាតប៉ុន្តែភ្លើ គ្មានអ្នកណាគោរពទេ។ យើងអាចធ្វើពុតជាឆ្លាត ដូចពួកតារាតាមទូរទស្សន៍បានដោយ post  status ឡូយៗ ឬថតវីដេអូវិភាគពីនេះពីនោះ ប៉ុន្តែយើងមិនអាចកុហកខ្លួនឯងបានទេ។ ភ្លើ មិនអាចលាក់បានយូរ។ ពេលគេស្គាល់យើងយូរបន្តិច គេគង់តែដឹងពីភាពភ្លើរបស់យើងមិនខាន។

246. ខ្ញុំធ្លាប់ជួបមនុស្សស្រីស្អាត តែភ្លើច្រើននាក់ណាស់ ហើយក៏ធ្លាប់ជួបមនុស្សស្រីមិនសូវស្អាត តែឆ្លាតច្រើននាក់ដែរ។ ពេលខ្ញុំនៅជិតមនុស្សស្រីឆ្លាត ខ្ញុំតែងតែលួចគំនិតដែលពួកគេមានមកសរសេរសៀវភៅជានិច្ច។ ពេលខ្ញុំនៅជិតមនុស្សស្រីស្អាតភ្លើវិញ ខ្ញុំតែងតែមើលអ្វី

ដែលគេបញ្ចេញជានិច្ច ចាត់ទុកថាកំដរភ្នែកលេង ព្រោះពួកគេគ្មានអ្វីបញ្ចេញក្រៅពីរបស់ប៉ុន្មានដុំហ្នឹងទេ។

247. ស្រី ឬប្រុសសុទ្ធតែមានខួរក្បាលដូចគ្នា ឱ្យតែចេះប្រើវាឱ្យត្រូវ យើងនឹងឈប់ភ្លើហើយ។

248. បើសិនជាក្នុងពេលមួយឆ្នាំ នៅតែគ្មានអ្វីផ្លាស់ប្តូរ បានន័យថា យើងមិនបានរស់នៅឱ្យត្រូវតាមក្បួនខ្នាតទេ។ ក្បួនខ្នាតនៃការរស់នៅ គឺផ្លាស់ប្តូរទៅមុខ។

249. អ្នកណាក៏ចូលចិត្តមើលឃើញខ្លួនឯងដើរទៅមុខដែរ។

250. ទំនួលខុសត្រូវរបស់ឪពុកម្តាយ គឺមិនត្រូវឱ្យកូនរបស់ខ្លួន មានភាពអាម៉ាស ដោយសារតែខួរក្បាលមិនចេះគិត និងភាពលោភលន់របស់ខ្លួនឯង។

251. បើយើងមិនហ៊ានលះបង់ យើងនឹងបាត់បង់។ អ្នកដែលមិនហ៊ានលះបង់ពេលវេលាដើម្បីរៀនជំនាញ នឹងត្រូវបាត់បង់ឱកាសក្លាយជាអ្នកជំនាញ។ អ្នកដែលមិនលះបង់ការខ្លាចអ្នកដទៃចេញបាន នឹងត្រូវរស់នៅជាទាសកររបស់អ្នកដទៃរហូត។

252. មានអ្នកអានតែម្នាក់ក៏បានដែរ កុំឱ្យតែរោងពុម្ពដើរខ្សែលើយើងបាន។

253. រោងពុម្ពមិនដែលខ្វល់ពីយោបល់របស់អ្នកនិពន្ធទេ។

254. យើងកាន់តែរៀនពីអ្វីថ្មី យើងកាន់តែលែងល្ងង់។

255. នៅពេលមនុស្សធំពេញវ័យ គេឈប់និយាយពីរឿងល្ងង់ហើយ គេចាប់ផ្ដើមផ្ដោតលើរឿង ភ្លើ វិញម្ដង។

256. មនុស្សល្ងង់ បានន័យថា គេមិនចេះអ្វីមួយ ឬមិនធ្លាប់បានស្គាល់អ្វីមួយ។ ចំណែកមនុស្សភ្លើបានន័យថា ដឹងហើយ ចេះហើយ តែមិនធ្វើ។

257. មានជំនាញនឹងដៃហើយ មិនដឹងថាអីបន្ត ក៏ជារឿងភ្លើមួយប្រភេទដែរ។

258. ល្ងង់ ជារឿងបណ្ដោះអាសន្នប៉ុណ្ណោះ។ ឱ្យតែបានរៀន បានអនុវត្តច្បាស់ជាលែងអីហើយ។ ប៉ុន្តែភ្លើ ជារឿងយូរអង្វែង ឬអាចនិយាយថាមិនអាចកែបានតែម្ដង។

259. មនុស្សភ្លើ មិនថាបានរៀនស្រុកក្រៅប៉ុន្មានឆ្នាំ មានបុណ្យសក្តិធំប៉ុណ្ណា ឬមានកូនប៉ុន្មាននាក់ ក៏នៅតែភ្លើដែរ ថាមិនត្រូវ កាន់តែភ្លើជាងមុនផង។ ខ្ញុំមិនច្បាស់ថា ភាពភ្លើរបស់មនុស្ស អាចរីកធំតាមអាយុរបស់មនុស្សដែរឬអត់ទេ ប៉ុន្តែបើតាមការសង្កេតក្រៅផ្លូវការ មនុស្សភ្លើ នឹងកាន់តែភ្លើជាងមុនពីមួយថ្ងៃទៅមួយថ្ងៃ។

260. មនុស្សភ្លើដែលបំផ្លាញខ្លួនឯង ជាមនុស្សភ្លើកម្រិតខ្ពស់បំផុត។

261. មនុស្សភ្លើ ច្រើនតែបានឡើងធ្វើជាអ្នកដឹកនាំ ដោយសារតែមានមនុស្សភ្លើច្រើនទៀតគាំទ្រ។ អ្នកទាំងអស់គ្នានៅចាំ ហ៊ីត្លែរទេ? បើមិនចាំ ក៏មិន

អីដែរ។ ចុះអូបាម៉ា នៅចាំទេ? តើពីរនាក់បានធ្វើឱ្យមនុស្សស្លាប់ប៉ុន្មាននាក់ដែរ? ហ៊ីត្លែរសម្លាប់ព្រោះចិត្តស្អប់ និងមហិច្ឆតាគ្រប់គ្រងពិភពលោក។ ចំណែកអូបាម៉ា សម្លាប់មនុស្ស ព្រោះត្រូវការលក់អាវុធ ដណ្ដើមទីផ្សារឱ្យធនាគារកណ្ដាល ដណ្ដើមប្រេង បំបិទការពិត និងមានមហិច្ឆតាគ្រប់គ្រងពិភពលោកដូចគ្នា។ ប៉ុន្តែហេតុអីក៏ពួកគេអាចធ្វើជាអ្នកដឹកនាំបាន? ដោយសារអ្នកដែលគាំទ្ររបស់ពួកគេ ជាមនុស្សប្រភេទតែមួយ។

262. មនុស្សភ្លើ ដែលរៀនបានច្រើន នឹងបង្កើតកម្រិតភ្លើរបស់ពួកគេថែមទៀត។

263. គ្រោះថ្នាក់របស់មនុស្សជាតិ កើតពីភាពភ្លើរបស់មនុស្សនេះឯង។

264. មនុស្សភ្លើ មានគ្រប់ទីកន្លែង ដូច្នេះកុំខ្លាចថាមិនបានជួប។

265. ការធ្វើខ្លួនឱ្យចុះចំណោមអ្នកដទៃ ជារឿងគួរឱ្យធុញទ្រាន់ ហើយធ្វើឱ្យជីវិតរបស់យើងគ្មានន័យ ដូចអង្គុយស្ដាប់ការសម្ភាសជាមួយអ្នកនយោបាយដែរ។

266. កិច្ចសន្យា ជាការព្រមព្រៀងដើម្បីប្រយោជន៍អ្វីមួយ។ មុននឹងធ្វើកិច្ចសន្យា ភាគីទាំងពីរបានគិតគូរ ធ្វើយ៉ាងឱ្យខ្លួនឯងបានផលចំណេញច្រើនបំផុត ហើយអាចដើរខ្សែលើភាគីម្ខាងទៀតបាន។ កិច្ចសន្យា ជាភស្តុតាងដែលបញ្ជាក់ថា ភាគីទាំងសងខាង គ្មានទំនុកចិត្តលើគ្នា និង

មិនឱ្យតម្លៃទៅលើភាពស្មោះត្រង់។ កិច្ចសន្យាក៏ជាអាវុធរបស់មនុស្ស មួយចំនួនដើម្បីយកឈ្នះដែរ។ អ្នកដែលពូកែធ្វើកិច្ចសន្យា តែងតែបង្កប់ ចំណុចលម្អិតមួយចំនួនដែលគេមិនចាប់អារម្មណ៍ ដើម្បីយកឈ្នះ នៅពេលចាំបាច់។

267. កុងត្រាភាគច្រើន មិនមានការស្មើភាពគ្នាទេ ព្រោះអ្នកជំនួញមិនចុះកុងត្រាដែលគ្មានប្រយោជន៍ច្រើនដល់ខ្លួនទេ។ អ្នកជំនួញ មានធាតុរបស់អ្នកនយោបាយមួយភាគ  គឺចង់ដើរខ្សែលើគេ។

268. ពាក្យល្អស្ដាប់ តែងតែមានន័យបង្កប់ជានិច្ច ជាពិសេសក្នុងកុងត្រា។

269. រោងពុម្ព មិនបានធ្វើឱ្យខ្ញុំទៅជាអ្នកសរសេរសៀវភៅទេ។ ខ្ញុំសរសេរសៀវភៅតាំងពីខ្ញុំមិនទាន់ស្គាល់រោងពុម្ពទៅទៀត។

270. កុំឱ្យតម្លៃលើកិច្ចសន្យាខ្លាំងពេក ត្រូវឱ្យតម្លៃលើពាក្យដែលយើងបានសន្យាជាមួយគេវិញ ល្អជាង។ កិច្ចសន្យា ជាផ្នែកមួយរបស់ច្បាប់ ហេតុនេះ វាមានគោលបំណងគាបសង្កត់មនុស្សដែលមិនបានចូលរួមបង្កើតវា។

271. អ្នកសរសេរពត៌មាន ជាអ្នកផ្ដល់ពត៌មានទៅដល់ប្រជាជន ហើយក៏ជាអ្នកពង្វក់ខួរក្បាលប្រជាជនដែរ។ ពួកគេបញ្ចូលរឿងអត់បានការជាច្រើន ទៅក្នុងជីវភាពប្រចាំថ្ងៃរបស់អ្នកអាន។

272. ស្រុកយើង ជាស្រុកពិសេសដែលមិនចូលចិត្តអ្វីដែលអាចដាស់ការគិតទេ។ យើងចូលចិត្ត ឱ្យគេវិភាគឱ្យគ្រប់ចំណុច និយាយប្រាប់គ្រប់ចំណុច ហើយធ្វើខ្លួនជាកន្ត្រក ដើម្បីដាក់កាកសំណល់គំនិតរបស់អ្នកដទៃ។ បើអ្វីដែលចូលទៅជាកាកសំណល់ អ្វីដែលចេញមកវិញក៏ជាកាកសំណល់ដែរ។

273. មនុស្សចំណាយពេលកាន់តែច្រើន លើការអានដែលគ្មានប្រយោជន៍ ពួកគេកាន់តែក្លាយជាមនុស្សគ្មានប្រយោជន៍។

274. ខ្ញុំសួរតាមត្រង់ចុះ ក្រោយពេលអានពត៌មានពីការចូលផ្ទះសំណាក់ហើយ តើយើងបានទទួលអ្វីមកវិញខ្លះ? តើយើងភ្លើដល់ថ្នាក់មិនដឹងថាគេចូលផ្ទះសំណាក់ដើម្បីធ្វើអីឬ?

275. អ្នកសារពត៌មាន មើលងាយខួរក្បាលរបស់អ្នកអាន ដូច្នេះទើបគេសរសេរតែពត៌មានមិនបានការឱ្យអាន ប៉ុន្តែពួកគេបែរជាភ្ញាក់ផ្អើលទៅវិញ នៅពេលដែលទទួលបានការគាំទ្រយ៉ាងច្រើនពីអ្នកអាន។ ធ្វើអាក្រក់ តែបានផលល្អ។

276. អ្នកសរសេរសៀវភៅ មិនស្ទូវឆ្លាតរឿងរកលុយទេ ព្រោះប្រើពេលទៅគិតពីអ្វីដែលត្រូវដាក់ក្នុងសៀវភៅច្រើនពេក។

277. ខ្ញុំសរសេរចេញពីចិត្ត។ បើចិត្តខ្ញុំប្រាប់ថា អាចម៌ ខ្ញុំសរសេរ អាចម៌ នៅក្នុងសៀវភៅរបស់ខ្ញុំ។

278. អ្នកសរសេរពត៌មាន គឺជាភាពអាម៉ាសមួយរបស់អ្នកនិពន្ធ ជាពិសេស បើសរសេរនៅក្រោមឥទ្ធិពលអំណាច និងលុយ។

279. សង្គមភ្លើ នឹងគាំទ្រអ្នកសរសេរពត៌មាន ហើយមិនរវល់នឹងអ្នកសរសេរសៀវភៅ។ ប៉ុន្តែសង្គមយើងមិនភ្លើទេ ព្រោះយើងមិនរវល់ទាំងពីរ។

280. បុគ្គលិក មិនមែនជាកងទ័ពទេ។ កងទ័ពជាមនុស្សដែលត្រូវគេយកមកប្រើ ដើម្បីប្រយោជន៍របស់អ្នកនយោបាយ និងអ្នកមានអំណាច។ ពួកគេត្រូវគេបោកដោយពាក្យថា "ប្រយោជន៍ជាតិ ឬប្រយោជន៍រួម" ដែលតាមពិត គឺប្រយោជន៍របស់តណ្ហាសោះ។ កងទ័ព ត្រូវមនុស្សលោភលន់អំណាច ទឹកលុយ និងកេរ្តិ៍ឈ្មោះ លាងខួរក្បាលរហូតដល់សុខចិត្តបូជាជីវិត ដើម្បីឱ្យអ្នកទាំងនោះមានឈ្មោះក្នុងប្រវត្តិសាស្ត្រ។ អ្នកដឹកនាំដែលទុកកូនចៅខ្លួនឯង ជាកងទ័ព គឺជាមនុស្សដែលលះបង់ជីវិតកូនចៅខ្លួនឯងដើម្បីបានសម្រេចគោលដៅរបស់ខ្លួន។ ខ្ញុំមិនពេញចិត្តនឹងទ្រឹស្ដីដឹកនាំប្រភេទអាចម៌ឆ្កែបែបនេះ ទើបខ្ញុំដាក់ពាក្យឈប់ធ្វើការ។

281. បើខ្ញុំសរសេរតាមអ្វីដែលគេបញ្ជាដដែល ខ្ញុំមិនមែនជាអ្នកនិពន្ធសៀវភៅទេ គេហៅថា អ្នកសរសេរតាមអាន។

282. ខ្ញុំរៀនសរសេរអ្វីដែលនៅក្នុងចិត្តរបស់ខ្ញុំចេញមក តែមិនប៉ះពាល់ដល់ត្រកូលមួយចំនួនក្នុងស្រុក ព្រោះភាពក្លាហានប្រើមិនបានផលទេជាមួយត្រកូលទាំងនោះ។ ខ្ញុំមិនក្លាហានបិទភ្នែកទេ។

283. នៅពេលដែលយើងធ្វើការជាក្រុម ត្រូវតែប្រាកដក្នុងចិត្តថា នេះជាក្រុមមួយពិតប្រាកដ ដែលអាចគាំទ្រយើងគ្រប់ពេលដែលជួបបញ្ហា។ មិនមែនយើងគាំទ្រគេគ្រប់ពេល ហើយដល់ពេលយើងមានរឿង គេរត់ចេញពីយើងនោះទេ។

284. បើធ្វើការជាក្រុម កុំធ្វើល្ងង់ និងកុំនៅគន្លៀតជញ្ជាំង។ អ្នកនៅក្នុងក្រុមទាំងអស់ ត្រូវមានសិទ្ធិស្មើគ្នា និងជួយទប់គ្នាទៅវិញទៅមក។

285. កុំខ្លាចអត់មានការងារធ្វើ បើចង់ខ្លាច ត្រូវខ្លាចថាខ្លួនឯងគ្មានសមត្ថភាពធ្វើការវិញល្អជាង។

286. ក្រុមការងារ ប្រៀបដូចជាបន្ទប់មួយដែលមានទ្វារចំហរ បើយើងមិនចូលចិត្តបន្ទប់នោះ ដើរចេញទៅ។ មុនពេលដើរចេញ ត្រូវបិទត្រចៀកបិទភ្នែកផង កុំឱ្យការគិតរបស់អ្នកដទៃមករារាំងការសម្រេចចិត្តរបស់យើង។

287. យើងត្រូវដឹងជាមុនសិនថា ការលក់ក្បាល កើតឡើងដោយសារតែភាពភ័យខ្លាច។

288. បើយើងមានជំនាញ យើងអាចលក់វាបាន ហើយយើងក៏មិនចាំបាច់ខ្វល់ពីការអត់ឃ្លានទៀតដែរ។ ឱ្យតែមានលុយចាយគ្រប់គ្រាន់ គឺអាចរស់បានហើយ។

289. អ្នកដែលលក់ក្បាលរួច នឹងពន្យល់យើងពីផលល្អនៃការលក់ក្បាល ហើយបើយើងជាមនុស្សលោភលន់ផងនោះ មិនយូរទេ ក្បាលរបស់យើងក៏ត្រូវគេទិញទៅដែរ។

290. ក្បាលមនុស្ស ឱ្យតែគេទិញបានម្តងហើយ វានឹងអស់តម្លៃរហូត។

291. យើងកាន់តែឱ្យតម្លៃទៅលើសេរីភាពខ្លាំងប៉ុណ្ណា យើងនឹងកាន់តែប្រើខួរក្បាលយើងច្រើនប៉ុននោះដែរ។ យើងកាន់តែប្រើខួរក្បាលច្រើនប៉ុណ្ណា យើងកាន់តែមិនដាច់ចិត្តលក់វាចេញ។ សេរីភាព អាចការពារខួរក្បាលឱ្យនៅកន្លែងដដែល។

292. អ្នកខ្លះមិនហ៊ានមើលភ្នែកខ្លួនឯងផង ព្រោះកំសាកខ្លាំងពេក។

293. ភាពក្លាហាន មិនសម្តៅទៅលើការថតវីដេអូជេរគេ ឬចូលធ្វើជាកូនអុកនយោបាយនោះទេ ព្រោះការធ្វើបែបនេះ គ្មានន័យអីទេ។

294. សង្គម ជាកន្លែងពង្វក់ខួរក្បាលមនុស្ស ហើយចុងក្រោយនឹងមានគេទិញក្បាលទាំងនោះយកទៅប្រើមិនខាន។ សង្គម ជាកន្លែងដែលមនុស្សរស់នៅផ្តុំគ្នាមែន តែក៏មានអ្នកដែលនៅពីលើនេះដែរ។ សង្គមបានបង្កើតឋានៈ និងពានរង្វាន់អត់បានការយ៉ាងច្រើនដើម្បីឱ្យមនុស្ស

ចង់បាន ហើយរកវិធីមិនឃើញក៏លក់ក្បាលតែម្តង។ យើងកាន់តែគិតពីឋានៈសង្គមប៉ុណ្ណា យើងកាន់តែមានឱកាសច្រើនដើម្បីបានឈ្មោះជាអ្នកលក់ក្បាលម្នាក់។

295. សុខចិត្តល្ងង់ តែកុំលក់ក្បាល។

296. កំហុសអីក៏គេអាចលុបលាងបានដែរ សូម្បីតែអ្នកដែលអុជអាលឱ្យកើតសង្គ្រាម ក៏ត្រូវគេរាប់ជាវីរបុរសបាន។ មានតែការលក់ក្បាលនេះទេដែលលាងមិនជ្រះ។ វាជាភាពអាម៉ាសមួយដែល មនុស្សម្នាក់លក់ក្បាលទៅឱ្យមនុស្សម្នាក់ទៀតដែលមានក្បាលដូចគ្នាដែរ។

297. ការរស់ស្រួល បានន័យថា រស់នៅដោយមិនបាច់មើលទឹកមុខគេ ឬទ្រពងអ្នកដទៃ។

298. ជំនាញ ជាច្រកផ្លូវសម្រាប់ចេញពីបញ្ហាស្ទើរគ្រប់ប្រភេទ។

299. ជំនាញ ធ្វើឱ្យគេគោរពយើង ហើយគេនឹងកាន់តែគោរពយើង បើយើងមានសមត្ថភាពអាចរកអ្នកដែលយល់ព្រមទិញជំនាញនោះ។

300. នៅស្រុកយើង គេពេញនិយមការលក់ក្បាល គេមិនខ្វល់ពីជំនាញទេ។ វាអាចមកពីគេមិនដឹងថា ការលក់ជំនាញ មានភាពថ្លៃថ្នូរជាងការលក់ក្បាល ឬក៏គេដឹងដែរ តែគេមិនត្រូវការភាពថ្លៃថ្នូរក៏ថាបាន។

301. នៅពេលយើងលក់ក្បាល យើងបានបាត់បង់ម្ចាស់ការលើខ្លួនឯង។ អ្វីដែលយើងធ្វើ គ្រាន់តែជាការគិត និងគម្រោងរបស់អ្នកដទៃប៉ុណ្ណោះ។

302. តើយើងមើលឃើញចំណុចខុសគ្នារវាងបុគ្គលិកដែលលក់ក្បាល និងបុគ្គលិកដែលលក់ជំនាញនៅក្នុងកន្លែងដែលយើងធ្វើការដែរទេ?

303. មនុស្សជាច្រើនសុខចិត្តលក់ក្បាល ព្រោះខ្ជិលក្នុងការលក់ជំនាញ។

304. ការលក់ជំនាញ អាចពិបាកជាងការលក់ក្បាល ប៉ុន្តែវាស្រួលចិត្តជាងឆ្ងាយណាស់។ ខ្ញុំលក់ជំនាញទៅឱ្យក្រុមហ៊ុន ដោយទៅធ្វើការពីព្រឹកដល់ល្ងាច។ ខ្ញុំយកអ្វីដែលខ្ញុំចេះទៅធ្វើការ ហើយគេបង់លុយឱ្យខ្ញុំដើម្បីដោះដូរគ្នា។ ខ្ញុំទុកក្រុមហ៊ុន ជាអតិថិជនដែលព្រមជឿជាក់លើមនុស្សដូចខ្ញុំ។ ខ្ញុំព្យាយាមរៀនបន្ថែមជំនាញរបស់ខ្ញុំ ដើម្បីធ្វើឱ្យអតិថិជនពេញចិត្ត និងបន្តទិញក្នុងរយៈពេលវែង។

305. ជំនាញរបស់ខ្ញុំ ជាអ្នកជួយទប់ខ្ញុំពីក្រោយ ដូច្នេះ ខ្ញុំប្តូរការងារប៉ុន្មានដងក៏វានៅតែអាចទ្រាំទ្របានដែរ។

306. មូលហេតុដែលខ្ញុំមិនលក់ក្បាល គឺដោយសារក្បាល គឺជាកន្លែងដែលបង្កើតជំនាញផ្សេងទៀត។ បើលក់ក្បាលបាត់ទៅហើយ ខ្ញុំច្បាស់ជាអស់ផ្លូវដើរទៀតមិនខាន។ លក់ក្បាលម្តង អាចបានលុយច្រើនមែន ប៉ុន្តែបើប្រៀបធៀបនឹងលុយដែលបានមកពីជំនាញ ដូចជាមិនចាញ់គ្នាប៉ុន្មានទេ។

307. ឱ្យតែក្បាលមិនទាន់លក់ចេញ យើងនឹងអាចរកឃើញអ្វីដែលអាចលក់បានបន្តទៀត។

308. រឿងដែលគួរឱ្យអស់សំណើចទាក់ទងនឹងការលក់ក្បាល និងលក់ជំនាញនេះ គឺមនុស្សដែលលក់ក្បាល គិតថាខ្លួនឯងកំពុងលក់ជំនាញ ហើយចេះតែឆ្ងល់ថា ហេតុអីក៏គេមិនចូលចិត្តខ្លួន។

309. សូម្បីតែក្បាលក៏លក់កើតដែរ តើនៅមានអ្វីដែលជារបស់ខ្លួនទៀតនោះ?

310. មិនថាយើងជិះឡានអីទេ មានផ្ទះធំប៉ុណ្ណាទេ បើលុយដែលយើងយកទៅទិញនោះ បានមកពីការលក់ក្បាលខ្លួនឯង របស់ទំនើបទាំងនេះនៅតែមិនអាចជួយលើកយើងឱ្យថ្លៃថ្នូរបានដែរ។ ខ្មែរយើងមានពាក្យសម្រាប់ហៅមនុស្សបែបនេះ គឺ "ថោកហួស" តែគេច្រើនប្រើក្នុងបទចម្រៀងប៉ុណ្ណោះ។

311. ក្រោយពេលលក់ក្បាលហើយ សូមមេត្តាកុំយកលេសដើម្បីលាងខ្លួនឯង។ កុំបន្ទោសគ្រួសារ កុំបន្ទោសអ្នកមានអំណាច ហើយកុំបន្ទោសព្រហ្មលិខិត ព្រោះយើងដឹងទាំងអស់គ្នាហើយថា បើឆ្កែវាមិនចង់ស៊ីអាចម៍ ទោះយកទៅដាក់ដល់មាត់វា ក៏វាមិនស៊ីដែរ តែបើវាចង់ស៊ីវិញ វាសុខចិត្តឈរចាំ ឬដើរហិតរកហើយ។

312. ខ្ញុំឱ្យយោបល់តែមួយទេ គឺ កុំជោរជាមួយអ្នកនយោបាយ។ គេជោរ គេបានប្រយោជន៍ យើងជោរតាមគេដែរ បានគេបោកឱ្យវិលខួរ។

313. នៅក្នុងឆាកនយោបាយ មានអ្នកទទួលប្រយោជន៍ និងអ្នកទទួលកំហុស។ អ្នកដែលទទួលប្រយោជន៍ គឺអ្នកនយោបាយ ចំណែកអ្នកដែលមិនបានប្រយោជន៍ ឬបានតិច គឺកូនអុកនយោបាយ។

314. អ្នកនយោបាយ ជាមេ ជាអ្នកគ្រប់គ្រងគ្រប់បែបយ៉ាង ចំណែកកូនអុកនយោបាយវិញ គឺគេប្រើសម្រាប់លេងអុកហ្នឹងហើយ។

315. ក្នុងនាមខ្ញុំជាកូនអុកនយោបាយម្នាក់ ខ្ញុំគ្មានពាក្យអីនិយាយអរគុណអ្នកនយោបាយទេ។ ខ្ញុំមានមោទនភាពចង់ងាប់ហើយរាល់ថ្ងៃនេះ។

316. ការបោះបង់ចោល ជារឿងអាម៉ាសបំផុតដែលមនុស្សបរាជ័យចូលចិត្តធ្វើ។

317. បើយើងចាំអ្នកដទៃមកជួយ យើងនឹងត្រូវចាំអស់មួយជីវិត។

318. យើងតែម្នាក់អាចធ្វើរឿងជាច្រើនបាន គ្រាន់តែយើងមិនធ្លាប់សាកល្បងប៉ុណ្ណោះ។ មនុស្សមួយក្តាប់តូច គេធ្លាប់ធ្វើហើយ។ ឥលូវនេះ មនុស្សមួយក្តាប់តូចនោះ កំពុងតែក្តោបក្តាប់មនុស្សដែលនៅសេសសល់។ តើយើងចង់ក្តាប់គេ ឬឱ្យគេក្តាប់យើង?

319. យើងជាមនុស្សតែម្នាក់ក្នុងលោក ដែលធ្វើរឿងគ្រប់យ៉ាងដើម្បីខ្លួនឯង។

320. ប្រភពចំណូល អាចប្រាប់យើងថា តើម្នាក់នោះជាមនុស្សល្អ ឬមនុស្សមិនសូវល្អ។

321. មនុស្សភ្លើ មិនសំដៅលើមនុស្សដែលមិនចូលសាលាទេ តែសំដៅលើមនុស្សដែលមិនប្រើខួរក្បាល។

322. ចោរលួច ចោរប្លន់ ប្រើវិធីលួចប្លន់ដើម្បីរកលុយ។ អ្នកដែលមានខ្លួនស្អាត ប្រើខ្លួនដើម្បីរកលុយ។ អ្នកដែលពូកែលើកជើង ប្រើភាពថ្លៃថ្នូររបស់ខ្លួនឯងដើម្បីប្តូរជាមួយលុយ។ អ្នកនៅក្នុងប្រព័ន្ធផ្សព្វផ្សាយ ប្រើពត៌មានពិត និងក្លែងក្លាយដើម្បីរកលុយ។ អ្នកធ្វើជំនួញ ប្រើលុយរបស់យើងគ្រប់គ្នាដើម្បីរកលុយ។ អ្នកនៅក្នុងសាសនា ប្រើសាសនាដើម្បីរកលុយ។ អ្នកនយោបាយ ប្រើនយោបាយដើម្បីរកលុយ។ កូនអុកនយោបាយ ក៏ប្រើនយោបាយដើម្បីរកលុយដែរ គ្រាន់តែត្រូវគេជេរច្រើនជាងអ្នកនយោបាយបន្តិច។ អ្នកដែលមិនជាប់នឹងនយោបាយ តែចំណាយពេលច្រើនជជែកពីរឿងនយោបាយ ប្រើកម្លាំងដើម្បីរកលុយ។

323. បើយើងមានសង្សារ យើងក៏មិនចង់ឱ្យអ្នកណាមករំលោភសង្សារយើងដែរ មិនថាអ្នករំលោភ ស្អាតជាងយើង ឬខ្លាំងជាងយើងទេ។ យើងក៏ត្រូវធ្វើបែបនេះជាមួយខួរក្បាលយើងដែរ។ សម្រាប់ពាក្យជាភាសាអង់គ្លេស យើងអាចនិយាយថា Don't let other people fuck your brain ។

324. ប្រព័ន្ធផ្សព្វផ្សាយចូលចិត្តរៀបរាប់ វិភាគ និងប្រាប់យើងពីរបៀបគិតគ្រប់យ៉ាង។

325. ដោយសារតែប្រជាជនចូលចិត្តធ្វើអ្វីយកមុខ ដូច្នេះក៏ពេញចិត្តឱ្យមេដឹកនាំដែលធ្វើការយកមុខដែរ។

326. វប្បធម៌យកមុខ វិលជារង្វង់ដូចកង់ ដូច្នេះខ្ញុំមិនច្បាស់ថាអ្នកណាជាមេភ្លើងនោះទេ។

327. អ្នកធំយកមុខតាមរបៀបអ្នកធំ ដោយបញ្ចេញមាសប្រាក់ ឬស្នាដៃក្លែងក្លាយរបស់គេ។ ចំណែកអ្នកតូចវិញ យកមុខដោយការទ្រពង និងការនិយាយអួត។

328. ក្នុងជីវិតមនុស្ស មិនដែលមានអ្នកណាធ្វើបានគ្រប់រឿងហើយទើបស្លាប់ទេ តែមានគេធ្វើគ្រប់រឿងសំខាន់បានមុនពេលគេស្លាប់។

329. អ្នកខ្លះសុខចិត្តនិយាយដើមគេ ក៏មិននិយាយពីរឿងអនាគតរបស់ខ្លួនដែរ។

330. នៅស្រុកយើង អ្នករត់ម៉ូតូឌុប និងពលករស្រុកក្រៅ យល់ដឹងរឿងនយោបាយជាងអ្នកធ្វើនយោបាយទៀត។

331. បើយើងកាន់តែគិតថាខ្លួនឯងយល់ យើងនឹងកាន់តែវង្វេង។ សូម្បីតែអ្នកដែលគេធ្វើនយោបាយផងនៅវង្វេងក្រឡា ចុះទម្រាំយើងដែលដឹងរឿងតាមកាសែត និងប្រព័ន្ធពង្វក់ខួរក្បាលហ្នឹង ហេតុអីក៏ច្បាស់ម្ល៉េះ? វាអាចមកពី យើងមានអំណួតលើខ្លួនឯងពេកក៏ថាបាន ព្រោះអំណួតជាមិត្តស្លាប់រស់របស់ជនជាតិយើងយូរមកហើយ។

332. អ្នកនយោបាយ និងកូនអុក មើលមួយភ្លែតដូចគ្នាណាស់ តែដល់ចុងក្រោយទើបដឹងថា អ្នកណាជាអ្នកនៅ។

333. ប្រព័ន្ធផ្សព្វផ្សាយ ជាឧបករណ៍សម្រាប់បង្វែរការចាប់អារម្មណ៍របស់មនុស្ស និងជាតុក្កតារបស់អ្នកធំ។

334. កុំជឿ Media កុំខ្វល់ពីវា បើយើងនាំគ្នាឈប់មើល ថ្ងៃណាមួយគង់តែបិទរោងទេ។

335. ដោយសារតែប្រជាជនខ្មែរ កំសាកមិនហ៊ានទទួលការពិត និងមានអំណួតលើចំណេះដឹងរបស់ខ្លួនពេក ទើបធ្វើឱ្យខ្មែរនៅតែប៉ុណ្ណឹង។

336. ឈប់ជឿអ្នកនយោបាយ និងកុំចំណាយពេលឈ្លោះគ្នាព្រោះតែអ្នកនយោបាយដែលមិនធ្លាប់ខ្វល់ពីយើង។

337. បើឃើញគេបំផ្លាញសង្គមហើយ កុំគាំទ្រគេទៀត។ ថ្ងៃនេះយើងបំផ្លាញសង្គម ថ្ងៃណាមួយ សង្គមនឹងបំផ្លាញយើងវិញមិនខាន។

338. ធ្វើអី កុំចាំតែគេមកដាស់ ទើបភ្ញាក់។

339. បើសិនជាខ្លួនយើងជាមនុស្សអាក្រក់ កុំនាំអ្នកផ្សេងទៀតឱ្យក្លាយជាមនុស្សអាក្រក់ជាមួយយើង។ បើធ្វើបែបនេះក៏ចាត់ទុកថាយើងបានជួយគេដែរ។

340. កុំឱ្យគេស្លាប់ ដោយសារតែភាពល្ងង់របស់យើង។ កុំឱ្យគេស្លាប់ ដោយសារតែយើងមិនចង់ចេះដឹង។ កុំឱ្យគេស្លាប់ ដោយសារតែយើងមិនហ៊ានទទួលការពិត និងកុំឱ្យស្លាប់ ដើម្បីឱ្យយើងបាន Share រូបភាពកាន់ទុកលើហ្វេសប៊ុក។

341. អ្នកណាក៏ចង់បានឈ្មោះជាមនុស្សល្អដែរ ទោះបីក្នុងចិត្តស្មោគគ្រោកប៉ុណ្ណាក៏ដោយ។ ប៉ុន្តែការគ្រាន់តែចង់បានឈ្មោះនេះហើយដែលវាបង្កជាបញ្ហា។

342. អំពើល្អ មិនប្រកាន់មនុស្សទេ។

343. ការធ្វើល្អយកមុខ ជាគ្រឿងលម្អរបស់មនុស្សបោកប្រាស់ ដែលយើងឧស្សាហ៍ឃើញអ្នកនយោបាយ អ្នកសិល្បៈ និងអ្នករកស៊ីមិនត្រឹមត្រូវយកមកប្រើ។

344. ឥលូវនេះ មានមនុស្សក្លែងក្លាយច្រើនណាស់នៅលើហ្វេសប៊ុក ដូច្នេះយើងមិនបាច់ចូលរួមនឹងគេ ក៏បានដែរ។

345. អ្នកក្នុងហ្វេសប៊ុកភាគច្រើនលាក់ចរិតពិត ប្រឌិតចរិតល្អ។

346. កុំជឿអ្វីដែលយើងបានឃើញនៅលើហ្វេសប៊ុក និងកុំជឿអ្នកដែលមានងារជា ឧកញ៉ា។

347. បើយើងរកឃើញអ្វីដែលត្រូវធ្វើពេញមួយជីវិត បានន័យថា យើងធំហើយ ថែមទាំងមានសំណាងទៀត។ អ្នកដែលមិនដឹងថាខ្លួនឯងរស់នៅដើម្បីអី កើតមកដើម្បីធ្វើតាមគេប៉ុណ្ណោះ មិនខុសពីអាយ៉ងទេ។

348. យើងរៀនបែងចែកឱ្យដាច់រវាង ក្បាលរឹងបែបកូនក្មេង និងក្បាលរឹងបែបមនុស្សធំ ព្រោះមនុស្សភាគច្រើនច្រលំប្រើតែបែបកូនក្មេងប៉ុណ្ណោះ។

349. បើគេធ្វើបុណ្យតែមុខកាម៉េរ៉ា បានន័យថា គេជាមនុស្សបោកប្រាស់ យកការធ្វើបុណ្យជាឈ្នាន់។

350. កុំជឿអ្វីដែលជនជាតិចិននិយាយ។ អ្នកទាំងអស់គ្នា អាចជឿលើសុភាសិត ឬទស្សនៈល្អៗរបស់ចិនបាន។

351. គ្រប់យ៉ាងដែលនៅជុំវិញខ្ញុំ សុទ្ធតែជាប្រព័ន្ធដែលគេរៀបចំទាំងអស់ ហើយប្រព័ន្ធបានបង្ខំឱ្យធ្វើអ្វីដែលខ្ញុំមិនចង់ធ្វើ។ ប្រព័ន្ធអប់រំ ប្រព័ន្ធច្បាប់ ប្រព័ន្ធឃោសនា និងប្រព័ន្ធសាសនា បានធ្វើឱ្យខ្ញុំច្រលំថាអ្វីជារឿងមិនត្រឹមត្រូវអស់។

352. គ្មានអ្នកណាសំខាន់សម្រាប់អ្នកណាទេក្នុងលោកនេះ។

353. បើអាយុច្រើនហើយ គឺដល់ពេលធំហើយ។

354. អ្នកនយោបាយ ចេះខិនបន្តិច នឹងត្រូវប្រជាជនថា ជាមនុស្សសាមញ្ញមិនចេះប្រកាន់ខ្លួន។ បើឱនក្បាលដល់ដីតែម្តង នឹងត្រូវគេចាត់ទុកជា

អ្នកស្នេហាជាតិ ស្រលាញ់ទឹកដីភ្លាម។ នេះមិនមែនជារឿងកំប្លែងទេ តែអាចសើចបាន។

355. មនុស្សកាលណាចេះឱនខ្លះ នឹងទទួលបានផល។ ខ្ញុំគិតថា មិនអាចបានលុយច្រើនដូចពួកដែលទ្រពងគេទេ ព្រោះបើប្រៀបធៀបគ្នា អ្នកចេះឱន លក់ខ្លួនតែមួយចំណិតប៉ុណ្ណោះ តែអ្នកទ្រពងវិញ លក់ទាំងដុលតែម្តង។ អ៊ីចឹងលុយក៏វាបានតាមហ្នឹងដែរ។

356. អ្វីដែលខ្ញុំខ្លាចជាងគេ គឺនៅអនាគត ខ្ញុំត្រូវរស់នៅជាមួយមនុស្សដែលពូកែទ្រពងគេទាំងនោះ។

357. មនុស្សទ្រពង គ្មានមនសិការទេ ទាំងក្នុងការងារ និងជីវិតខ្លួនឯង។

358. ការទ្រពង នឹងធ្វើឱ្យអ្នកចេះដឹងម្នាក់ ក្លាយទៅជាមនុស្សគ្មានតម្លៃ ឬក៏មានតម្លៃដែរ តែធូរថ្លៃ។

359. យើងត្រូវចាំថា ការលើកជើងអំពើអាក្រក់ ក៏ជាអំពើអាក្រក់មួយប្រភេទដែរ។

360. អ្នកណាក៏អាចសរសេរសៀវភៅបានដែរ តែមិនមែនមនុស្សទាំងអស់សុខចិត្តចំណាយពេលសរសេរនោះទេ។

361. ការសរសេរក៏ដូចជាការយកទឹកឆ្នោតដែរ គឺត្រូវការឱ្យវាស្រក់តក់ៗ ហូតដល់ពេញ។ បើប្រញាប់ យើងអាចបញ្ចប់វាបានមែន តែអត្ថន័យវា មិនទាន់ចប់ទេ។

362. ការសរសេរ អាចបង្ហាញពីចរិតមនុស្ស។ យើងត្រូវចាំថា អ្នកអានអាច ដឹងថាយើងជាមនុស្សលោក់ពុត នៅពេលយើងសរសេរអ្វីមិនស្មោះត្រង់ ដូច្នេះបើមិនអាចសរសេរដោយស្មោះត្រង់បាន កុំសរសេរ។

363. ពុតចិនកុំត្រាប់ ច្បាប់ចិនសឹមរៀនតាម។

364. ចិនជាមនុស្សលោក់ពុត តែចូលចិត្តយកទ្រឹស្តីល្អមកបាំងមុខ។ ចិន ជា មនុស្សអួត អឿ និងពូកែអាងណាស់។ ពួកនេះ អាងលុយ អាងខ្សែ និង អាងពូជខ្លួនឯងជាចិន។ ពួកនេះដឹងថា ខ្មែរឱ្យតម្លៃចិន ហេតុនេះទើប លើកតម្កើងខ្លួនឯងខ្ពស់ជាងគេ។

365. ខ្មែរឃើញចិនមាន គិតថាចិនល្អ តែមិនដឹងថាតើគេបានលុយមកពីណា និងមិនដឹងថាចិនមានរឿងពីក្រោយខ្នងអ្វីខ្លះ។

366. បើរាប់ពី១ដល់១០ ភាពអាក្រក់របស់ចិន នៅត្រង់លេខ៩ ព្រោះពួកនេះ ខូចណាស់ លួចដកលេខ១០យកទៅលាក់ទៀត។

367. ខ្ញុំមិនបង្រៀនឱ្យអ្នកទាំងអស់គ្នាស្អប់ជនជាតិចិនទេ តែខ្ញុំមិនចង់ឱ្យអ្នក ទាំងអស់គ្នា រៀនតាមរឿងអាក្រក់ដែលពួកនេះធ្វើ។

368. ចង់ធ្វើមនុស្សល្អ ងាយស្រួលណាស់ គឺកុំធ្វើតាមពួកចិនទៅបាន ហើយ។

369. ចាំពេលណា ខ្ញុំរៀនចេះបោកមនុស្ស ចាំខ្ញុំយករឿងនយោបាយមក សរសេរម្តង។

370. ការអួត មិនបានបិទផ្លូវអ្វីទេ តែវាជាការវាយបំបាក់ជើងខ្លួនឯងមិនឱ្យ ដើរកើតតែម្តង ។

371. ឱ្យតែបានបង្កើតកូនចេញមកក្រៅ កំណត់ថាជាម៉ែឪហើយ ចំណែក ទង្វើផ្សេងទៀតក្រោយពេលកើតមក ទើបជាអ្នកកំណត់ថា មានគុណ ឬអត់។

372. កុំជឿអ្វីដែលឮតគ្នា ឬគេថាតាមគ្នាខ្លាំងពេក ព្រោះវាធ្វើឱ្យយើងងាយ នឹងចាញ់បោកគេ ។ រឿងអីក៏មានប្រភពដើមដែរ បើរកមិនទាន់ឃើញ កុំ ទាន់ជឿ ។

373. បើយើងជួបនឹងម៉ែឪដែលគ្មានគុណ មិនមែនជាកំហុសយើងទេ តែបើ យើងធ្វើខ្លួនជាម៉ែឪដែលគ្មានគុណ ទើបជាកំហុសយើងទាំងស្រុង។

374. កុំបោះចោលមេរៀនល្អ ដោយសារបុគ្គលដែលផ្តល់មេរៀននោះ ជា មនុស្សដែលយើងមិនចូលសចិត្ត។

375. កុំខ្មាសអៀន ដោយសារតែធ្វើតាមគន្លឹះរបស់មនុស្សដែលគ្មានឈ្មោះ។ អ្វីដែលសំខាន់ គឺប្រើទៅបានផលឬអត់ប៉ុណ្ណោះ។

376. ការលាក់ធាតុពិតរបស់ខ្លួនឯង ក៏ជារឿងកំសាកមួយដែរ។

377. ខ្ញុំឯកភាពនឹងសម្ដីថា "មនុស្សមិនមែនជាកោះ មិនអាចរស់នៅម្នាក់ឯងបាន" តែមនុស្សអាចរស់នៅតាមវិធីខ្លួនឯងបាន។ វិធីដែលយើងរស់នៅនឹងកំណត់ថា យើងរីករាយដល់កម្រិតណា។

378. ការចាំតែធ្វើតាមគេ នឹងបង្កើតភាពស្មុគ្រស្មាញដល់យើង ហើយធ្វើឱ្យយើងទទួលបានភាពរីករាយក្លែងក្លាយ។

379. អ្នកដទៃធ្វើគ្រប់យ៉ាងដើម្បីគេសប្បាយចិត្ត ហើយយើងក៏ត្រូវតែធ្វើឱ្យខ្លួនឯងសប្បាយដែរ។

380. យើងមិនចាំបាច់តែកាន់ដាវ ពាក់អាវក្រោះ ទើបក្លាយជាអ្នកក្លាហានទេ គ្រាន់តែហ៊ានធ្វើរឿងឱ្យខ្លួនឯងសប្បាយ ក៏ហៅថាក្លាហានដែរ។

381. ជីវិតរបស់យើងខ្លីណាស់ និងមិនអាចទាយទុកពីពេលបញ្ចប់បានទៀត ដូច្នេះ កុំរស់នៅដោយមិនសប្បាយចិត្ត និងធ្វើជាមនុស្សកំសាក។

382. អ្នកនយោបាយ មិនមែនជាខ្ញុំបម្រើរាស្ត្រទេ រាស្ត្រទេដែលជាខ្ញុំបម្រើអ្នកនយោបាយ។ ឈប់ឆ្កួត និងពាក្យលើក្រដាសទៀតទៅ រៀនមើលការពិតខ្លះផង។

383. អ្នកដែលយកសាសនាជាឈ្នាន់ ដឹងថា សាសនាមានប្រយោជន៍។ អ្នកដែលត្រូវសាសនាបោកប្រាស់ ក៏ជឿថា សាសនាមានប្រយោជន៍ដែរ។ មើលឃើញចំណុចខុសគ្នាទេ? គេដឹង យើងជឿ។ ដឹង និងជឿ បញ្ជាក់ថា អ្នកណាជាជនរងគ្រោះ។

ការចូលចិត្តពុទ្ធទស្សនៈ និង ស្វែងយល់ពីវា ជារឿងផ្សេង ព្រោះមនុស្សច្រើនណាស់ដែលចូលចិត្តទស្សនវិជ្ជា តែការយកលុយទៅឱ្យគេបោក ជារឿងមិនសមសោះ។

384. កុំធ្វើចិត្តធ្ងន់ជាមួយសាសនា ប្រយ័ត្នធ្ងន់ពេក ងើបខ្លួនឯងលែងរួច។

385. ពេលខ្ញុំសរសេរទាក់ទងនឹងសាសនា ខ្ញុំគ្មានបំណងសរសេរឱ្យអ្នកដែលកាន់សាសនាងប់ ដូចជា លោកសង្ឃ ឬអ្នកដែលពឹងលើសាសនាដើម្បីរស់ អានទេ។ ខ្ញុំសរសេរឱ្យអ្នកដែលមានការស្ទាក់ស្ទើរក្នុងរឿងនេះអាន ដើម្បីគេស្រួលសម្រេចចិត្ត។

សូមកុំអានអ្វីដែលគេមិនសរសេរឱ្យយើងអាន ព្រោះវាគ្មានប្រយោជន៍ដល់យើង។ ហើយបើជ្រុលអានហើយ កុំយកទុកក្នុងចិត្តខ្លាំងពេក ព្រោះអ្វីដែលខ្ញុំសរសេរ មិនមែនដើម្បីផ្គាប់ចិត្តអ្នកនៅក្នុងសាសនាទេ។

អានហើយ ខឹងនឹងខ្ញុំ ប្រៀបដូចជា យើងទៅលួចមើលប្ដីប្រពន្ធគេ

រួមភេទ ហើយមកខឹងនឹងប្ដីដែលប្រើក្បាច់មិនត្រូវចិត្តខ្លួនឯងអ៊ីចឹង។ គេធ្វើអីតែប្ដីប្រពន្ធគេសោះ យើងអត់មានពាក់ព័ន្ធផង មកខឹងរកងាប់ស្អីដែរ?

386. បើយើងជា fan របស់សាសនា យើងគួរតែដឹងថា ការរករឿងគេមុនមិនមែនជាចរិតរបស់ព្រះទេ ដូច្នេះ បើជ្រុលជាធ្វើពុតជាជឿទៅហើយសូមធ្វើតាមចរិតនេះផង។

387. ខ្ញុំមានសិទ្ធិបញ្ចេញយោបល់ គេមានសិទ្ធិមិនអានគេមានសិទ្ធិបញ្ចេញយោបល់ ខ្ញុំមានសិទ្ធិ block វិញ។សិទ្ធិមានដូចគ្នា ចេះប្រើដូចគ្នា។

388. ប្រើហ្វេសប៊ុក ត្រូវចេះ block អ្នកដែលយើងមិនចូលចិត្ត។ កុំខាតពេលនឹងមនុស្សដែលមិនចូលចិត្តយើង ហើយកុំខាតពេលនឹងមនុស្សដែលយើងមិនចូលចិត្ត។ ហ្វេសប៊ុក ប្រើសម្រាប់ភ្ជាប់ទំនាក់ទំនង តែមិនមែនជាមួយមនុស្សគ្រប់គ្នាទេ។

389. របៀបលេងហ្វេសប៊ុក កុំ ឱ្យគេបញ្ឆាក្បាលយើង

=> ចូលមក comment ដោយមិនអាន block ចោល

=> ចូលមក comment ដោយមិនចេះគិត block ចោល

=> កុំ block អ្នកshare ទោះបីគេសរសេរអាក្រក់ពីយើងក៏ដោយ ព្រោះវាឡើង reach

=> កុំដោយសារតែគេ comment ហើយយើងតបទៅគេវិញ ដោយមិន

ដឹងគោលដៅ ។ ហ្វេសប៊ុក មានប្រយោជន៍ណាស់ បើយើងចេះប្រើវាឱ្យត្រូវពេល។

390. Atheist អាចនឹងមើលឃើញបញ្ហាបានឆ្ងាយជាងអ្នកដែលកំពុងតែជាប់ខ្លួននឹងសាសនា។

391. ការពិត នឹង ធ្វើឱ្យមនុស្សកំសាក និង ភ្លើៗ ចង់ចូលមកបញ្ចេញយោបល់តបត។

392. បើមានឱកាសបង្រៀនសិស្ស កុំភ្លេចបង្រៀនសិស្សពីមហិច្ឆតាផង។ ធ្វើយ៉ាងណាឱ្យសិស្សមើលឃើញចំណុចល្អនៅក្នុងមេរៀនដែលគេអាចយកទៅធ្វើអ្វីធំបាន។ កុំបង្រៀន ឱ្យតែចប់ បង្រៀន ឱ្យគេមានផ្លូវដើរមិនចេះចប់ដោយខ្លួនឯង ទើបល្អ។

393. អ្នកណាក៏អាចធ្វើរឿងដែលមានប្រយោជន៍បានដែរ ឱ្យតែច្បាស់ថាចង់ធ្វើពិតមែន។

394. គេអ្នករកស៊ី គេសរសេរសៀវភៅពីការរកស៊ី។ អ្នកនយោបាយ សរសេរសៀវភៅពីរឿងនយោបាយ។ អ្នកនៅក្នុងសិល្បៈ សរសេរសៀវភៅពីសិល្បៈ និងសិច។ អ្នកដែលឆ្លងកាត់សង្គ្រាម សរសេរពីការរងទុក្ខក្នុងសង្គ្រាម។

ខ្ញុំជាខ្ញុំគេ សរសេរសៀវភៅពីការធ្វើខ្ញុំគេ។ ខ្ញុំធ្វើខ្ញុំបរទេសផង ខ្មែរឯង

ផង អស់៦ឆ្នាំហើយ ដូច្នេះខ្ញុំមានវិធីធ្វើការខ្លះដែលអាចប្រើបានផល។ កុំរំពឹងថាមានការលើកជើង ឬអែបអបក្នុងនោះអី ព្រោះខ្ញុំមិនចេះ ហើយទោះបីជាចេះ ក៏ខ្ជិលធ្វើដែរ។

395. ខ្ញុំគេសម័យថ្មី ចេះគិតរកផ្លូវដើរ។

396. ខ្ញុំសរសេរសៀវភៅដោយផ្អែកលើការពិតដែលខ្ញុំដឹង មិនមែន ការពិតដែលអ្នកទាំងអស់គ្នាដឹងនោះទេ ហេតុនេះវាខុសគ្នា។ យើងត្រូវបែងចែកឱ្យដាច់រវាងអ្នកនិពន្ធ និងខ្លួនយើង។ វាមិនអាចស្របគ្នាទាំងស្រុងនោះទេ។ បើចង់ស្រប មានតែសរសេរសៀវភៅដោយខ្លួនឯង។

397. ខ្ញុំសរសេរសៀវភៅមួយក្បាលប្រើពេលមួយខែ ឬពីរខែមែន តែខ្ញុំ សន្សំបទពិសោធន៍ដោយត្រូវទៅធ្វើការនេះ ធ្វើនោះជាច្រើនឆ្នាំ ទើបបានពាក្យមកសរសេរ។

398. យើងអាចចែកអ្នកនិពន្ធជាបីប្រភេទ ដោយផ្អែកទៅលើតួអង្គក្នុងរឿង
=> ប្រភេទ hero (ព្យាយាមសរសេររឿងល្អពីខ្លួនឯង និង ធ្វើគ្រប់យ៉ាងឱ្យមានភាពវិជ្ជមាន)។
=> ប្រភេទ villain (ព្យាយាមសរសេរដើម្បីពង្វក់អ្នកដទៃ និង វាយប្រហារទៅលើរឿងល្អ។ ភាគច្រើន ជាការសរសេរលាបពណ៌ក្នុងរឿងនយោបាយ)។
=> ប្រភេទ antihero (សរសេរពីរឿងគ្រប់យ៉ាង ទោះបីរឿងនោះត្រឹមត្រូវ

ឬមិនត្រឹមត្រូវក៏ដោយ។ វាយប្រហារអ្នកណាក៏បាន លើកពីអ្វីក៏បាន។ សរសេរដោយមិនខ្វល់ និងមិនទាមទារឈ្មោះថា ល្អ)។

ខ្ញុំស្ថិតក្នុងប្រភេទទីបី។ អ្វីដែលខ្ញុំសរសេរ គឺផ្អែកលើការមើលឃើញរបស់ខ្លួនឯង ដូច្នេះមិនថាវាត្រូវ ឬមិនត្រូវទេ គឺខ្ញុំនៅតែសរសេរដដែល។ អ្វីដែលខ្ញុំសរសេរអាចមិនត្រូវ១០០% ដូច្នេះអ្នកអាន ត្រូវគិតដោយខ្លួនឯង ឬស្រាវជ្រាវបន្តដោយខ្លួនឯងដើម្បីបាន ចម្លើយពិត។

ល្អ ក៏ខ្ញុំមិនចង់ធ្វើ អាក្រក់ក៏ខ្ញុំមិនចង់ធ្វើ ខ្ញុំចង់នៅចំណុចដែលអាចបត់បាន អាចល្អពេលដែលខ្ញុំចង់ អាចអាក្រក់ពេលដែលត្រូវការ។

399. មិនមែនអ្នកនិពន្ធទាំងអស់ សុទ្ធតែជា មនុស្សល្អ ឬត្រឹមត្រូវនោះទេ។ អ្នកទាំងអស់គ្នាអានសៀវភៅដែលចេញពីរោងពុម្ពច្រើនពេក ហេតុនេះបានជាភ្លេចថា ពិភពសៀវភៅ ដូចជាពិភពរបស់យើងរស់នៅអ៊ីចឹង។ អ្នកនិពន្ធមានចរិតប្លែកគ្នា និងមានគោលដៅខុសគ្នាច្រើនណាស់ ដូច្នេះពេលអាន យើងត្រូវបើកចិត្តឱ្យទូលាយ និងបង្ខំខួរក្បាលយើងឱ្យគិតផង។ បើយើងភ្លេចខ្លួន អ្នកនិពន្ធនឹងចូលទៅបញ្ឆោខួរក្បាលយើងបានហើយ។

400. សៀវភៅរបស់ខ្ញុំ សរសេរដោយខ្លួនឯងទាំងអស់ ហេតុនេះទើបខ្ញុំ មិនចង់ ឱ្យវាទៅជា សៀវភៅពេស្យាដែលអ្នកណាក៏មានសិទ្ធិកូពីចែកគ្នា។

401. ហេតុអីរោងពុម្ពមិនបោះសៀវភៅដែលនិយាយពីរឿងកុហករបស់សាសនា?

គេមិនបោះ ព្រោះ៖

=> អត់មានអ្នកសរសេរ។

=> ទោះបីមានអ្នកសរសេរ ក៏គេមិនបោះដែរ។ អ្នករោងពុម្ព ជឿលើសាសនា។

=> គេមិនចង់ ឱ្យយើងចេះគិតបែងចែកការពិត និងរឿងក្លែងក្លាយច្រើនពេកទេ។

=> វាប៉ះពាល់ដល់ទីផ្សារ។ ស្រុកយើង មានអ្នកជឿលើសាសនាស្ទើរតែទាំងអស់។

រោងពុម្ពមិនលូវង់បោះលុយចោល ដើម្បីពន្យល់អ្នកអាន ឱ្យចេះគិតនោះទេ។ សាសនា ជាឫសគល់ធំមួយក្នុងការជឿលើអ្វីផ្សេងទេ។ មនុស្សអាច ជឿលើសាសនាបាន អ្វីផ្សេងទៀត ក៏ងាយនឹងជឿដែរ។

402. ចៀមមួយហ្វូង កំពុងជជែកគ្នា។ ចៀម អួតគ្នាពីរឿងម្ចាស់វា។ ចៀមឈ្លោះគ្នា ព្រោះវាគិតថា ម្ចាស់វាល្អជាងម្ចាស់ចៀមផ្សេង។ ចៀម ឈ្លោះគ្នាកាន់តែខ្លាំង។ ម្ចាស់វា ដើរមករុញពួកវាចូលទ្រុង ហើយបបួលគ្នាទៅផឹកស្រា។ ចៀមឈ្លោះគ្នាបន្តទៀត។

=> សន្និដ្ឋាន ៖ ចៀមចូលចិត្តធ្វើឬកដូចមនុស្ស។

403. ចាញ់បោកគេ មធ្យមទេ ងំត្រង់បកមកខាំអ្នកជួយប្រាប់។

404. បើយើងមិនមែនព្រះ សូមកុំតាំងខ្លួនជាព្រះ។

405. ខ្ញុំគ្មានសង្ឃឹមថាបានទៅនិព្វានទៀតទេ ដូច្នេះរាល់ថ្ងៃខ្ញុំប្រឹងរស់ឱ្យមានន័យ ហើយមិនរំពឹងថា ដល់តែស្លាប់ទៅ ទើបបានសុខដូចអ្នកដទៃដែរ។

406. អ្នកនយោបាយ ឆ្លាតៗណាស់ ទុកចិត្តមិនបានទេ។

407. កូនខ្លះឆ្កួតណាស់ ចេះមើលតែរឿងទេ ចាំដល់ម៉ែទៅបាត់បាននាំគ្នាយំដូចក្នុងរឿង។ រៀនតាម រឿងបានល្អណាស់។

408. ឃើញគេយល់ នាំគ្នាធ្វើជោរយល់ដែរ ព្រោះខ្លាចគេថា ភ្លើ។ ការជោរតាមគេហ្នឹងហើយ ដែលហៅថាភ្លើ។ ខ្លាចភ្លើធ្វើអី បើភ្លើរួចហើយហ្នឹង?

409. កុំមានជំនឿ ដោយខ្លួនឯងមិនយល់ កុំធ្វើជាយល់ ដោយជោរតាមគេ។

410. ខ្ញុំគ្មានបំណងមកធ្វើការយឺតទេ បំណងរបស់ខ្ញុំគឺមិនមកធ្វើការតែម្តង។ កុំចោទខ្ញុំផ្តេសផ្តាស។

411. ភ្លើដល់គល់ = នៅមិនសុខ យកលុយទៅឱ្យគេ ហើយជៀលអ្នកដែលមិនធ្វើដូចខ្លួន ថាភ្លើ។

412. ស្រុកចេះដឹង កាន់ទុក្ខឱ្យអ្នកដែលនាំទុក្ខដល់ មនុស្សពេញមួយស្រុក។

413. យ៉ាងហោចណាស់ខ្ញុំមិនបាច់យកលុយឱ្យគេ ហើយហៅគេថាលោកប្រធាន។

414. ធ្វើការ និងរកស៊ី ខុសគ្នាតែមួយចំនុចទេ គឺធ្វើការអាចលួចខ្ជិលបាន ហើយបានលុយដដែល តែរកស៊ី បើលួចខ្ជិលដឹងតែអត់ហើយ។

415. "មកពីមានប្រយោជន៍ហ្នឹងហើយ បានជាគេមិនចាប់អារម្មណ៍ធ្វើ" ទ្រឹស្តីស្រុកខ្ញុំ។

416. ធ្វើជាមនុស្ស ត្រូវមានតម្លៃ ហើយតម្លៃនោះត្រូវតែរកមកដោយខ្លួនឯង។

417. មិនជឿលើសាសនា ល្អជាងធ្វើពុតជាជឿសាសនា។

418. ល្ខោនមិនទាន់អស់ប្រជាប្រិយទេ ព្រោះនៅមានអ្នកចូលចិត្តមើលពេក។ ល្ខោនខ្លះល្អមើល ល្ខោនខ្លះលេងមកដូចអត់សូវយល់។

419. ហេតុអ្វីបានជាគេយកទស្សនវិជ្ជា ទៅបង្កើតជាសាសនា? ទស្សនវិជ្ជាសម្រាប់មនុស្សគិត ធ្វើឱ្យមនុស្សបែកប្រាជ្ញាក្នុងផ្លូវល្អ។ សាសនាសម្រាប់មនុស្សជឿ ធ្វើឱ្យលែងមានសំណួរបន្ត តែក៏អាចធ្វើឱ្យបែកប្រាជ្ញាដែរ គឺបង្កើតរបស់ផ្សេងៗដើម្បីលក់បានលុយ។ ហេតុអីយករបស់ល្អ និងមានប្រយោជន៍ ទៅបង្កើតរបស់មិនល្អ និងគ្មានប្រយោជន៍?

420. មិនចេះខ្លួនឯង ត្រូវថាឱ្យខ្លួនឯងទើបត្រូវ។

421. បើយើងមិនចេះខ្លួនឯង កុំបន្ទោសអ្នកដទៃថានិយាយជ្រៅពេក។

422. ប្រទេសមួយដែលឆ្លុតនឹងសង្គ្រាម ងប់តែនឹងសង្គ្រាម។ ប្រទេសមួយដែលឆ្កួតនឹងវិទ្យាសាស្ត្រ ងប់តែនឹងវិទ្យាសាស្ត្រ។ ប្រទេសមួយដែលឆ្កួតនឹងសាសនា ងប់តែនឹងនិពាន្វ។ រស់នៅចង់តែទៅនិពាន្វ។ ពេលរស់មិនបាច់ប្រឹងធ្វើអីទេ រស់ខ្ជិលៗទៅ ស្លាប់បាត់បានស្គាល់និពាន្វហើយ។ បើគិតទៅ គឺរស់ដើម្បីពេលស្លាប់ប៉ុណ្ណោះ។

423. ចំណេះដឹងដែលយើងបានពី Internship មានច្រើនណាស់ ៖

=> រៀនវិធីបោកមនុស្សប្រើនៅក្នុងពិភពការងារ។

=> ដឹងថា ជំនាញ អាចជួយយើងបានដោយមិនបាច់ធ្វើការឱ្យគេទទេ ឬបានកម្រៃតិច។

=> ដឹងថា internship និងធ្វើការមែនទែន អត់មានអីខុសគ្នា ប៉ុន្តែសម្រាប់ថៅកែ វាខុសគ្នាត្រង់ចំនួនលុយ។

=> ជួយតម្រង់ផ្លូវការងារឱ្យយើងខ្លះដែរ។

Internship មានល្អ មានអាក្រក់ តែបើយើងមានសមត្ថភាពធ្វើការហើយ បំភ្លេចរឿងដាក់ធ្វើ Intern ចោលទៅ។ ធ្វើមែនទែន យកលុយមែនទែន ស្រួលចិត្តជាង។

424. អាន២នាទី គិត៣នាទី សរុប៥នាទី។ ៥នាទី មានអីពិបាកធ្វើ។

425. ពេលខ្លះ អ្នកជំនួញក៏គេមិនលាក់យើងដែរ គ្រាន់តែយើងមិនបើកភ្នែក បើកខួរគិតដោយខ្លួនឯង។ ពេលខ្លះគេមិនចង់បោកយើងទេ តែយើងនៅតែចូលទៅឱ្យគេបោកទៀត។ ធ្វើបាបគេមែន អាងតែគេមាន នាំគ្នាធ្វើជាជនរងគ្រោះឱ្យគេបោករហូត។

426. បើមិនចេះ ជួយប្រាប់ឱ្យត្រង់មក ស្រួលដោះស្រាយទាំងអស់គ្នា។

427. ចង់ឱ្យគេមើលងាយដែរទេ? ធ្វើភ្លើទៅ បានហើយ។

428. រៀនខ្លួនឯងខ្លះ កុំឱ្យគេមើលងាយ។

429. បរាជ័យ មានអីគួរខ្លាច ខ្លាចជាងគេ គឺសាសនា ក្លាយជាមុខជំនួញដ៏ធំ។

430. មនុស្សប្រុសដែលយំនៅពេលបរាជ័យ ជាមនុស្សស្រីដែលដុះសាច់លើសមួយចង្កោម។

431. អ្នកជឿលើសាសនា ប្រៀបដូចជាជឿលើមនុស្សស្រីដែលស្រលាញ់តែលុយ។ អស់លុយពេលណា សាសនាសុំលាហើយ។

432. ជាតិសាសន៍ណាក៏ដោយ កុំចង់ប្រជែងជាមួយខ្មែរក្នុងរឿងធ្វើខុសតាមគ្នា។ គ្មានគីឡូទេ។

433. ខំសែនដូចចិន ដូនតាសប្បាយចិត្ត ជួយឱ្យបានធ្វើខ្ញុំចិន។

434. អ្នកនិពន្ធ គួរតែមានការងារធ្វើឱ្យជាប់លាប់មួយ។ ទីមួយ គឺដើម្បី អាចចិញ្ចឹមក្រពះបាន។ ទីពីរ គឺប្រមូលបទពិសោធន៍ពីជីវិតខាងក្រៅ។

435. ប្រទេសកម្ពុជា ជាប្រទេសសេរី។ ប្រើអំណាច ក៏សេរី និយាយអី ក៏សេរី ធ្វើអីក៏សេរី លើកលែងតែចង់ធ្វើរឿងប្រឆាំងនឹងអ្នកធំប៉ុណ្ណោះ។

ប្រទេសយើងផ្តល់សេរីភាពជាងគេ គឺ សាសនា។ ទោះបីរដ្ឋយកពាក្យសាសនា ទៅដាក់ក្នុងបាវចនាជាតិ ហើយឆ្លៀតបញ្ជាក់ថា "ព្រះពុទ្ធសាសនា ជាសាសនារបស់រដ្ឋ" ក៏ដោយ ក៏យើងនៅតែមានសេរីភាពនេះដែរ។ យើងអាចមិនជឿបាន ប៉ុន្តែយើងមិនចង់រើខ្លួនពីជំនឿសាសនានេះ។ យើងខ្លាចរើទៅមានបាប។

បើយើងទុកពាក្យណែនាំក្នុងពុទ្ធសាសនា ជាទស្សនៈវិជ្ជានៃជីវិត ហើយធ្វើតាមពាក្យទាំងនោះ វាមិនជាបញ្ហាទេ។ តែបើជឿតាមអ្នករៀបចំសាសនា ឬអ្នកដែលបានមុខមាត់ និងលុយកាក់ ដោយសារសាសនាវិញ គឺជារឿងអាម៉ាស់មួយរបស់យើង។ យើងគួរតែខ្មាសគេ ព្រោះយើងមានខួរក្បាលនឹងគេដែរ បែរជាឱ្យគេបោកបាន ។ សាសនា ជារបស់ free សោះ តែបែរជាត្រូវចំណាយលុយលើសពី១០% ទៅចូលរួម។

436. បើយើងអានច្រើន យើងក៏មានឱកាស គិតច្រើនដូចគ្នា។

437. ចង់រៀនពីមនុស្សឆ្លាត អាចអានតាមសៀវភៅ ឬមើលបទសម្ភាសន៍នៅលើអ៊ីនធឺណេត។ ចង់រៀនពីមនុស្សភ្លើ ចូលមើលហ្វេសប៊ុកមួយភ្លែតទៅ ឆាប់ចេះណាស់។

438. ភ្លើ ជាភ្លើង។ ភ្លើងនេះមិនត្រឹមតែដុតខ្លួនឯងទេ ថែមទាំងដុតអ្នកដទៃទៀត។

439. ខ្លាចស្អីមិនខ្លាច ទៅខ្លាចមិនបានភ្លើដូចគេ។

440. គិតវិជ្ជមានខុសរបៀប នឹងក្លាយជាគ្រោះថ្នាក់វិញមិនខាន។

441. សង្គមស៊ីវិល័យ ជាសង្គមដែលចេះគិត និងមិនជឿតាមការបញ្ចោររបស់អ្នកដទៃ តែភាពស៊ីវិល័យនៅស្រុកយើង បែរជាមានន័យផ្ទុយពីគេទៅវិញ។

442. សង្គមបោះលុយ = អ្នកមានក៏បោះលុយ អ្នកក្រក៏បោះលុយ។ អ្នកមានបោះលុយដើម្បីបានប្រយោជន៍ អ្នកក្របោះលុយដោយអត់បានអ្វីទាំងអស់។

443. ខ្ញុំសរសេរពាក្យថា"ពង្វក់ខួរក្បាល" ដើម្បីជួយដាស់អ្នកដែលមានខួរក្បាលប៉ុណ្ណោះ ដូច្នេះអ្នកដែលអត់ខួរ កុំធ្វើពុតជាខឹងនឹងខ្ញុំអី។ បើយើងអត់ខួរផង គេមកពង្វក់យើងតាមណាកើត?

444. អ្វីដែលខ្ញុំសរសេរ ទាំងក្នុងសៀវភៅ ប្លុក ឬលើហ្វេសប៊ុក គឺសម្រាប់អ្នកមានខួរប៉ុណ្ណោះ ព្រោះខ្ញុំចង់ឱ្យគេគិតលេងៗ។ យើងដឹងហើយថា "អ្នកមានខួរ ចូលចិត្តគិតណាស់" ដូច្នេះដើម្បីមានគេទទួលស្គាល់ ខ្ញុំត្រូវសរសេរអ្វីដែលធ្វើឱ្យពួកគេបានគិត។ ខ្ញុំមិនចេះផ្គាប់មនុស្សអត់ខួរទេ ដូច្នេះសូមទោសផង។

445. មនុស្សសំខាន់លើសុខភាព និងការគិត។ បើសុខភាពល្អ មានរាងកាយរឹងមាំ តែការគិតមិនបានមួយចំណិតឆ្អែ ក៏គេមិនអាច ហៅថាមនុស្សដែរ។

446. អត់ខួរ ជាទំនោររបស់សង្គម ព្រោះមនុស្សអត់ខួរ ងាយរស់នៅ មិនចេះខ្វាយខ្វល់ មុខក្រាស់ និងស្លាប់ទៅដោយគ្មានអ្វីស្ដាយ។

447. បើយើងគិតថាយើងចេះគិត កុំតបនឹងមនុស្សអត់ខួរ។

448. ពេលទៅធ្វើការ ត្រូវសួរគេឱ្យច្បាស់ តើយើងនៅក្រោមបង្គាប់របស់អ្នកណា? បើយើងមិនច្បាស់ថា អ្នកណាជាអ្នកបញ្ជាយើងបាន យើងក៏មិនដឹងទៅរកអ្នកណាដែរ ពេលដែលជួបបញ្ហា។

ធ្វើការ និងបញ្ហា មានសម្លេងជូនគ្នា មិនមែនជារឿងចៃដន្យទេ។ បើគ្មានបញ្ហាទេ បង្កើតខ្លះទៅ ដើម្បីសប្បាយខ្លួនឯង។ បញ្ហាមិនធ្វើឱ្យយើងសប្បាយទេ តែពេលដោះស្រាយបញ្ហាបាន ធ្វើឱ្យយើងសប្បាយចិត្ត។

449. មនុស្ស៣ប្រភេទ ៖

១ អានសៀវភៅជំនួញមួយជីវិត ធ្វើខ្ញុំគេមួយជីវិត

២ អានសៀវភៅជំនួញម្តងម្កាល ធ្វើជំនួញពេញមួយជីវិត

៣ មិនអានសៀវភៅតែម្តង

សំណួរ ៖ តើហេតុអីបានជាលោកសង្ឃអានសៀវភៅជំនួញ?

450. ហេតុអីខ្ញុំសរសេរសៀវភៅ? ព្រោះខ្ញុំចង់លក់សៀវភៅ។

ហេតុអីខ្ញុំចង់លក់សៀវភៅ? ព្រោះខ្ញុំសរសេរសៀវភៅ។

សំណួរស្រដៀងគ្នា ចម្លើយស្រដៀងគ្នា។

451. មានរឿងមួយដែលរដ្ឋាភិបាលអាចធ្វើបាន ហើយយើងមិនអាច ធ្វើបាន គឺ ធ្វើរឿងខុសដោយស្របច្បាប់។ មិនថាខុសប៉ុណ្ណាទេ ក៏ច្បាប់ត្រូវតែស្របតាមរដ្ឋាភិបាលដែរ។

452. បើគេយកសាសនាមកធ្វើជាមុខរបររកលុយ ហើយយើងក៏ដឹងពីរឿងនេះដែរ ប៉ុន្តែ នៅតែយកលុយឱ្យគេទៀត តើយើងជាមនុស្សបែបណា? ពាក្យបច្ចេកទេសគេហៅថា អត់ខួរ។

453. ផលប្រយោជន៍មួយដែលយើងទទួលបាន ក្រោយពេលបោះសាសនា និងជំនឿដែលយើងមិនយល់ចោល គឺ ពេលវេលា។ យើងមានពេលដើម្បីធ្វើរឿងដែលសំខាន់ជាងនេះសម្រាប់ខ្លួនយើង។ ការទៅអង្គុយស្តាប់អ្វីដែលយើងមិនយល់ ជារឿងខាតពេល។ ពេលវេលាដែលយើង

រស់នៅ មានតម្លៃណាស់ កុំអស់លុយហើយ អស់ទាំងពេលវេលាទៀត។

454. តាមពិត ពុទ្ធសាសនា ជាទស្សនវិជ្ជាមួយអំពីជីវិតមនុស្ស ប៉ុន្តែ ទស្សនវិជ្ជា រកលុយមិនសូវបាន ព្រោះមនុស្សមិនសូវយល់ ។ ដូច្នេះ ដើម្បីបានលុយ មានតែប្តូរពីទស្សនវិជ្ជាមកជាសាសនាវិញ ព្រោះបើសិនជា សាសនា មិនថាអ្នកនោះយល់ឬមិនយល់ទេ គេនៅតែជឿ គេនៅតែហុចលុយឱ្យ។

ឥលូវសាកសួរទៅមើល តើអ្វីជាទៅនិពាន្ទ? ចេះតែថាតាមគ្នាប៉ុណ្ណោះ គ្មានអ្នកណាយល់ពិតប្រាកដទេ? ថាតាមគ្នា មិនសូវអី ប៉ុន្តែគិតថាខ្លួនឯងនឹងបានទៅដល់និពាន្ទទៀតទើបបានយ៉ាប់។

តើយើងអាចយល់ម៉េចបាន បើមិនដែលបានឃើញ មិនដែលបានទៅផង? ការជឿលើអ្វីដែលខ្លួនឯងមិនយល់ ជារឿងចម្លែកមួយ តែសម្រាប់អ្នកដែលជឿសាសនា មិនចម្លែកទេ។ មនុស្ស ជា robot សាសនា។ គេបញ្ជាមកយ៉ាងម៉េច ធ្វើយ៉ាងហ្នឹង។

455. មិនមែនឱ្យតែកោរសក់ ហើយស្លៀកស្បង់ ជាមនុស្សល្អទាំងអស់ទេ។

456. ការចែករង្វាន់ក្នុងស្រាបៀរ ជាការអបអរពេលមនុស្សម្នាក់កំពុងសម្លាប់ខ្លួន។ មើលឃើញដែរទេ? គេយកយើងមកធ្វើ promotion ប៉ុណ្ណោះ។

គេមិនខ្វល់ពីយើងទេ។ ពេលយើងស្លាប់បាត់ នឹងមានមនុស្សមកផឹកជំនួសកន្លែងយើងទៀតហើយ។

457. បើយើង ជាអ្នកទីផ្សារ យើងត្រូវតែដើរតាមទំនោរទីផ្សារ តែបើយើងគ្រាន់តែ ជាមនុស្សដែលមិនចេះធ្វើអី និងចាំតែដកលុយឱ្យគេទេ ការដើរតាមទំនោរទីផ្សារ គ្រាន់តែការបង្អួតភាពភ្លើរបស់យើងប៉ុណ្ណោះ។

458. យកលុយប្រជាជន ដើម្បីបង្កើតអំណាចខ្លួនឯង។ ពេលបានអំណាចហើយ ទាត់ប្រជាជនចោល។

459. សង្គមខ្មែរយើងដូចសង្គមអាមេរិចដែរ។ បើគេសរសើរ ជោរយកងាប់យករស់ តែបើគេថាភ្លើវិញ ប្រឆាំងភ្លាម។ ខ្ញុំសប្បាយចិត្តណាស់ដែលបានរស់នៅក្នុងប្រទេសដែលភ្លើស្រដៀងហ្នឹងអាមេរិចដែរ។

460. លួចរៀនខ្លួនឯង ទើបសប្បាយជាង។

461. ទម្លាប់អាក្រក់បំផុតរបស់ជនជាតិយើង គឺបន្ទោសគេ ទាំងខ្លួនឯងគ្មានបានធ្វើអ្វីទាំងអស់។

462. សាសនាអ្វីក៏មិនល្អដែរ ឱ្យតែសាសនានោះមានអ្នកដឹកនាំត្រឹមត្រូវហើយ។ លុយ លុយ លុយ លុយទិញសាសនា …

463. ប្រយោជន៍នៃសាសនា គឺ អឺ....អេ....អូ....អុញ។
គឺជួយឱ្យខ្ញុំមានឧទាហរណ៍សម្រាប់ប្រើក្នុងសៀវភៅ។

464. សាសនា ជាប្រភពលេសដ៏ធំបំផុត។

465. ស្តង់ដារពីរ មានគ្រប់ទីកន្លែង។ ខ្ញុំក៏មានស្តង់ដារពីរដែរ។ បើមនុស្សចេះដឹងមកនិយាយជាមួយខ្ញុំ ខ្ញុំនិយាយដោយការគោរព។ បើមនុស្សភ្លើៗមកនិយាយជាមួយខ្ញុំ ខ្ញុំនិយាយដោយគោរពខ្លួនឯង។

466. បើខ្ញុំមិនធ្វើការឱ្យរដ្ឋ តើខ្ញុំនៅពីក្រោមរដ្ឋដែរទេ? ខ្ញុំគិតថានៅពីក្រោមដូចគ្នា ហើយក៏បានចូលរួមដើម្បីរដ្ឋដូចគ្នាដែរ ព្រោះគេកាត់លុយខ្ញុំចូលពន្ធដាររដ្ឋរាល់ខែ។

467. គេអត់ខួរផង នៅគេធ្វើការរដ្ឋបាន ចុះយើងមានខួរប៉ុណ្ណឹងដែរ រឿងអីរកការងារធ្វើមិនបាន? នេះជាការជម្រុញចិត្តរបស់ខ្ញុំពេលរកការងារធ្វើ។

468. អត់បេះដូង មនុស្សមិនអាចរស់បានទេ តែបើអត់ខួរ អាចរស់បានហើយមានកាតពាក់នៅនឹងកទៀតផង។

469. នៅក្នុងការងារ ឬការរៀនសូត្រ អ្នកដែលចេះច្រើនជាងអាចជួយបង្រៀនអ្នកដែលចេះតិចជាង ឬមិនចេះសោះបាន។ ចែករំលែកចំណេះដឹងដើម្បីឱ្យចេះដូចគ្នា។

បើនិយាយពីភាពភ្លើរបស់មនុស្សវិញ ត្រូវធ្វើផ្ទុយគ្នា។ អ្នកដែលភ្លើច្រើនជាង ត្រូវរៀនតាមអ្នកដែលភ្លើតិចជាងវិញ។ ចែករំលែកថ្នាំពន្យាដើម្បីកុំឱ្យភ្លើច្រើនគ្នាពេក។

អ្នកដែលគេភ្លើតិចជាងខ្ញុំ គេនឹងជួយបង្រៀនខ្ញុំ។ ខ្ញុំនឹងស្ដាប់ហើយកត់ទុក ដើម្បីយកមកសរសេរសៀវភៅលក់។ ចំណែកអ្នកដែលភ្លើច្រើនជាងខ្ញុំ ចង់និយាយអីក៏និយាយទៅ ព្រោះសៀវភៅរបស់ខ្ញុំសរសេរជាភាសាមនុស្ស មិនសរសេរជាភាសាភ្លើទេ។

470. ការពារខួរក្បាលយើងឱ្យបាន ទើបគេហៅថាមនុស្ស។

471. តើអ្នកទាំងអស់គ្នាធ្លាប់និយាយរឿងសាសនានៅក្នុងផ្ទះដែរទេ? បើធ្លាប់តើត្រូវគេធ្វើឱ្យបិទមាត់ ឬយើងជាអ្នកបិទមាត់គេ? គ្រួសារដែលមិននិយាយពីជំនឿដោយបើកចំហរ ជាគ្រួសារផ្ដាច់ការ និងមិនឱ្យតម្លៃខួរក្បាលរបស់សមាជិកផ្សេងទៀត។ ខ្ញុំនិយាយសឹងតែរាល់ថ្ងៃ ទោះបីពេលខ្ញុំនិយាយគេដើរចេញអស់ក៏ដោយ។

472. ស្គាល់ profile ស្គាល់ cover តែមិនស្គាល់ចិត្ត។ មនុស្សជំនាន់ហ្វេសប៊ុក បង្កើតរឿងដែលគេស្មានមិនដល់។

473. បើកុំតែនៅក្នុងសាសនា មានបាយស៊ីស្រួល មានលុយសន្សំ និងបានចាស់ៗឱនក្បាលគោរព ស្មានតែអ្នកមិនជឿអស់ហ្នឹងរត់ចូលទៅបួសកើតអី?

474. ខ្ញុំមើលងាយមនុស្សដែលគ្មានសមត្ថភាពរកលុយ ហើយរត់ចូលទៅរកសាសនាដើម្បីសន្សំលុយណាស់។ ពេលសន្សំគ្រប់ ក៏បណ្ដុះសក់ដើរ

ចេញ ធ្វើជាមនុស្សពាលនៅក្នុងសង្គមវិញ។ អ្នកទាំងអស់គ្នាឆ្ងល់ដែរទេ ហេតុអីលោកសង្ឃដែលសឹកមួយចំនួនធំ មានចរិតពាល?

475. ខ្ញុំចង់ការប្រពន្ធ ខ្ញុំសន្សំលុយដោយសមត្ថភាពដែលខ្ញុំមាន។ ខ្ញុំមិនទៅបួស ដើម្បីបោកលុយអ្នកណាទេ។ បួសដើម្បីសន្សំលុយការប្រពន្ធ ជាបាបកម្មដ៏ធំមួយ ព្រោះមើលងាយភាពឆ្លាតរបស់អ្នកដែលចូលលុយ មើលងាយសាសនាដែលខ្លួនឯងជ្រកក្បាលពីក្រោម និងជាពិសេសក្លាយជាមនុស្សបោកប្រាស់។ គួរឱ្យស្តាយមែន លើលោកនេះមិនមាននរក។

476. គុណក៏ត្រូវដឹង ទោសក៏ត្រូវចាំ។

477. កុំដោយសារតែគុណតូចមួយ ហើយសុខចិត្តឱ្យធ្វើទោសដាក់យើងរាប់មិនអស់នោះទេ។ ស្គាល់គុណ ស្គាល់ទោស ទើបយើងរស់បានសុខ។

478. មនុស្ស ៣ប្រភេទដែលចូលចិត្តទ្រពងគេ ៖

=> មនុស្សដែលមិនមានជំនាញច្បាស់លាស់

=> មនុស្សលោភលន់ជ្រុល

=> មនុស្ស ដែលគិតខ្លីពេក

ខ្ញុំស្គាល់ភាគច្រើនជាមនុស្សប្រភេទទី១ ប៉ុណ្ណោះ ព្រោះនៅកន្លែងដែលខ្ញុំធ្វើការមានច្រើនគួរសមដែរ។

479. គំនិតខុសគ្នា មិនបាច់ពិភាក្សាច្រើននោះទេ។

480. រុញការឈើចាប់មួយឡែកសិន ពេលកំពុងធ្វើការងារ។

481. អ្នកអានដែលដើរតាមរោងពុម្ព បញ្ជាក់ថា អ្នកអាននោះខ្វះអ្វីម្យ៉ាង ហើយ។

482. ចង់បានចំណេះដឹងថ្មី អានសៀវភៅ។
ចង់ដឹងមនុស្សល្បី អានសៀវភៅ។
ចង់លំហែខួរក្បាល អានសៀវភៅ។
ចង់គេចពីមនុស្សដែលយើងមិនចូលចិត្ត អានសៀវភៅ។

483. បើយើងមានពេលលេងហ្វេសប៊ុកលើទូរស័ព្ទ យើងក៏មានពេលអាន សៀវភៅដែរ។

484. ចេះសួរសំណួរ ទើបអានសៀវភៅបានយូរ។

485. រៀនអានសៀវភៅ គឺរៀនពន្យល់ខ្លួនឯង។

486. រឿងនិទាននិយាយពីសត្វ តែសម្រាប់មនុស្សអាន។

487. ជនជាតិគេមកស្រុកយើងធ្វើជាមេ ជនជាតិយើងទៅស្រុកគេ ធ្វើជាខ្ញុំ។

488. យើងមិនត្រូវចាំគេមកបង្រៀនយើងឱ្យចេះអានសៀវភៅនោះទេ។

489. ទុកកិត្តិយសឱ្យឪម៉ែ ផ្តល់តម្លៃដល់ខ្លួនឯង ឈប់ទ្រពងអ្នកដទៃ។

490. បានធ្វើរឿងតូចមួយ ប្រសើរជាងមិនបានធ្វើអ្វីសោះ។

491. កុំទើសគេ ដោយសារយើងគ្មានសមត្ថភាពធ្វើបានដូចគេ។

492. បើយើងចង់រៀនជិះកង់ កុំទៅសួរអ្នកដែលមិនធ្លាប់ជិះកង់ ត្រូវសួរអ្នកដែលធ្លាប់ជិះ ឬកំពុងតែរៀនជិះ។

493. បើចង់ឱ្យសមត្ថភាពលេចធ្លោ យើងត្រូវបញ្ចេញវាមកក្រៅ។

494. បើសិនជាសង្គមយើងឱ្យតម្លៃទៅលើភាពត្រឹមត្រូវ ប្រហែលមិនសូវមានអ្នកចង់ចូលធ្វើការរដ្ឋទេ។

495. មានរឿងជាច្រើនដែលយើងត្រូវយកទស្សនៈ ″សក់អ្នកណា ក្បាលអ្នកហ្នឹង″ មកប្រើ។

496. នយោបាយ ជាសិល្បៈនៃការក្រឡុកប្រជាជនឯង។

497. បើយើងទុកលេស ជាហេតុផល យើងក៏ទុកខួរក្បាល ជាអាចម៍ឆ្កែផងដែរ។

498. មនុស្សកំសាក កាន់តែអានិត កាន់តែបានចិត្ត និងកាន់តែកំសាកលើសមុនទៀត។

499. មនុស្សដែលចំណាយពេលច្រើនលើការអានអ្វីដែលគ្មានប្រយោជន៍ គេនឹងក្លាយជាមនុស្សគ្មានប្រយោជន៍។

500. កុំធ្វើខ្លួនជាភាពអាម៉ាសរបស់ឪពុកម្តាយយើង។

# ទំព័រចុងក្រោយ

ជាចុងក្រោយ ខ្ញុំសូមអរគុណអ្នកដែលបានចំណាយពេលនៅសល់មកអានសៀវភៅរបស់ខ្ញុំ។ ខ្ញុំសង្ឃឹមថា អ្នកទាំងអស់គ្នានឹងទទួលបានប្រយោជន៍ត្រលប់ទៅវិញខ្លះដែរ។ បើមិនទាន់បានទេ ហើយមិនទាន់អស់ចិត្ត អាចត្រលប់ទៅអានម្តងទៀតបាន។

ខាងក្រោមនេះ ជាសៀវភៅផ្សេងទៀតដែលខ្ញុំបានចេញផ្សាយរួចហើយ៖

សៀវភៅ ៤ឆ្នាំ

សៀវភៅ ចរិតឆ្កែ

សៀវភៅ រើសមកទុកវិញ

សៀវភៅ ជីវិតយើងខ្លីពេក

សៀវភៅ រៀនតាមឆាវឆាវ

សៀវភៅ ជម្រើសទីពីរ

សូមអរគុណ។

# អំពីអ្នកនិពន្ធ

ឈ្មោះ ហួត សេងគៀ។ ខ្ញុំជាអ្នកសរសេរសៀវភៅ ហើយក៏ចូលចិត្ត អានសៀវភៅដែរ។ ខ្ញុំចំណាយពេលដែលសល់ពីការងាររបស់ខ្ញុំ ដើម្បី ឆ្លៀត សរសេរសៀវភៅទាំងអស់របស់ខ្ញុំ។ ខ្ញុំមិនមានលទ្ធភាពបោះ ការងារចោល ហើយសរសេរពេញម៉ោងនោះទេ។ ខ្ញុំក៏មិនភ្លើទៅធ្វើបែប នេះដែរ ព្រោះបើខ្ញុំធ្វើបែបនេះមែន ស្មើនឹងបញ្ចប់ការសរសេររបស់ ខ្លួនឯងហើយ។

ឥលូវនេះខ្ញុំធ្វើការផ្នែកក្រាហ្វិចឌីហ្សាញ និង e-Learning នៅក្នុង ក្រុមហ៊ុនបរទេសមួយ។ ខ្ញុំមិនមែនជាអ្នកជំនាញទេ។ ខ្ញុំរៀនបណ្ដើរ ធ្វើការបណ្ដើរប៉ុណ្ណោះ។ ខ្ញុំស្អប់សាលារៀន តែចូលចិត្តការរៀន ដោយខ្លួនឯង ដូច្នេះការងារក្នុងផ្នែកនេះត្រូវជាមួយនឹងខ្ញុំណាស់។

ខ្ញុំមិនជឿលើសាសនា នយោបាយ ឬការឃោសនាអ្វីទាំងអស់។ ខ្ញុំជឿ លើខ្លួនឯង ជឿលើធម្មជាតិ ជឿលើជីវិតសត្វ និងជឿលើភាពជា មនុស្ស។ ខ្ញុំមិនចូលចិត្តអ្នកណាមកនិយាយប៉ះនឹងជំនឿរបស់ខ្ញុំ។ មិនថាមានសក់ឬអត់សក់ សក់ខ្មៅ ឬសក់ស សក់វែង ឬសក់ខ្លីទេ ខ្ញុំ

មិនទុកមុខឱ្យទាំងអស់ បើនិយាយភ្លើដាក់ខ្ញុំ។ ខ្ញុំមិនចូលចិត្តមនុស្សភ្លើទេ។ ខ្ញុំជឿថា មនុស្សមានខួរក្បាល ដូច្នេះ គួរតែប្រើវាឱ្យបានច្រើនជាពិសេសមុននឹងនិយាយ ឬធ្វើអ្វីមួយទៅកាន់អ្នកដទៃ។

ខ្ញុំជាមនុស្សដែលងាយចុះសម្រុងនឹងគេណាស់ ពេលដែលខ្ញុំបិទមាត់ តែពេលណាខ្ញុំបញ្ចេញយោបល់ទៅ អ្នកដទៃនឹងដើរចេញមិនខាន។ ខ្ញុំមិនចូលចិត្តធ្វើពុត ឬនិយាយយកគួរទេ។ ខ្ញុំចូលចិត្តនិយាយចំៗ និងនិយាយចំមុខមនុស្សដែលត្រូវនិយាយទៀតផង។ ខ្ញុំមិនចូលចិត្តធ្វើអីឱ្យតែល្អមើលនោះទេ ខ្ញុំចង់ឃើញប្រយោជន៍របស់វា។

ខ្ញុំមិនមែនជាមនុស្សត្រឹមត្រូវតាមអ្វីដែលសង្គមចង់បាននោះទេ ព្រោះខ្ញុំមិនគោរពអ្វីដែលគេដាក់មកទេ។ ខ្ញុំមានគោលការណ៍របស់ខ្ញុំ ហើយខ្ញុំមិនខ្វល់ពីអ្វីដែលអ្នកដទៃនិយាយទេ។ ខ្ញុំជាមនុស្សឈ្លើយដែរពេលខ្លះ ព្រោះខ្ញុំមិនចង់ឱ្យគេដើរខ្សែលើខ្ញុំរហូតពេក។

អ្វីដែលអ្នកទាំងអស់អាននៅក្នុងសៀវភៅ គឺជាចរិតរបស់ខ្ញុំនៅខាងក្រៅហើយ។ បើធ្វើការប្រៀបធៀបសៀវភៅដែលខ្ញុំសរសេរពីមុន ចរិតខ្ញុំមានការផ្លាស់ប្ដូរច្រើនណាស់។